បញ្ញមត្តានំ ហត្ថិនិយាសតានំ[1] កប្បាបេត្វា រញ្ញោ ច អាភេហាណីយំ ជាតំ រញ្ញោ មាតរញ្ច អជាតសត្តុស្ស វេទេហីបុត្តស្ស បដិវេទេសិ កប្បិតានំ ខោ តេ ទេវ ហត្ថិយានានំ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ បញ្ច-សុ ហត្ថិនិយាសតេសុ[2] បច្ចូឋាយ ឥត្ថិយោ អាភេ-បេត្វា អាភេហាណីយំ ជាតំ អភិរុហិត្វា ឧក្កាសុ ជា-លិយមានាសុ ពលកាយេន ចតុរង្គិនិយា សេនាយ មហច្ចរាជានុភាវេន យេន ជីវកស្ស កោមារភច្চស្ស អម្ពវនំ តេន បាយា-សិ ។ អថខោ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេ-ទេហីបុត្តស្ស អវិទូរេ អម្ពវនស្ស អហុទេវ ភយំ អហុ ឆម្ភិតត្តំ អហុ លោមហំសោ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ តីតោ សំវិគ្គោ លោមហដ្ឋ-ជាតោ[3] ជីវកំ កោមារភច្ចំ ឯតទវោច កច្চិ មំ សម្ម ជីវក ន វញ្ចេសិ កច្চិ មំ សម្ម ជីវក ន បលម្ភេសិ កច្চិ មំ សម្ម ជីវក ន បច្চត្ថិកានំ ទេសិ

---

១ ឧ ហត្ថិនិកាសតានិ ។ ២ ហត្ថិនិកាសតេសុតិ កត្ថចិ ។ ៣ លោ-មហំសជាតោតិ កត្ថចិ ។

ជាធំកង់ដែនមគធៈ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយក៏ឲ្យ
រៀបចំដំរីញីតាំងឡាយចំនួន ៥០០ ផង ឲ្យរៀបចំដំរីឈ្មោលជាព្រះទីនាំង
របស់ព្រះកដាផង រួចហើយក៏ចូលទៅក្រាបបង្គំទូលព្រះភាគអដាតសត្តុវៈ-
ទេហីបុត្ត ជាធំកង់ដែនមគធៈថា បពិត្រព្រះសម្មតិទេព យានដំរីតាំងឡាយ
ទុំព្រះអង្គបានឲ្យរៀបចំ សម្រាប់ព្រះអង្គជាស្រេចហើយ ឥឡូវនេះ សូម
ព្រះអង្គកំណត់កាលដ៏គួរនឹងព្រះកដដំណើរចុះ ។ លំដាប់នោះ ព្រះភាគ
អដាតសត្តុវៈទេហីបុត្ត ជាធំកង់ដែនមគធៈ ឲ្យពួកស្ត្រីឡើងដំរីញី ១ ម្នាក់
គ្រប់តាំង ៥០០ ហើយទ្រង់ឡើងគង់លើដំរីឈ្មោលជាព្រះទីនាំង មាន
ពួកពាជបុរសកាន់គប់ក្ដឹង ហែចេញអំពីក្រុងពាជគ្រឹះ ដោយពាជានុភាព
ដ៏ប្រសើរ ស្ដេចសំដៅទៅត្រង់ទីវត្តអម្ពវ័ន របស់ដីវកកោមារកត្យ ។ ក្នុង
កាលដែលព្រះភាគអដាតសត្តុវៈទេហីបុត្ត ជាធំកង់ដែនមគធៈ ទ្រង់ស្ដេច
ទៅដល់ទីដិតនៃវត្តអម្ពវ័ន ក៏មានសេចក្ដីខ្លាច មានសេចក្ដីតក់ស្លុត មាន
សេចក្ដីព្រឺពេមកើតឡើង ។ លុះព្រះភាគអដាតសត្តុវៈទេហីបុត្ត ជាធំកង់ដែន
មគធៈ កើតមានសេចក្ដីខ្លាច សេចក្ដីតក់ស្លុត ព្រឺពេមកើតឡើងហើយ
ទើបទ្រង់មានព្រះបន្ទូលនឹងដីវកកោមារកត្យដូច្នេះថា នែដីវកៈ ជាសំឡាញ់
អ្នកមិនបញ្ឆោតខ្ញុំទេឬ នែដីវកៈ ជាសំឡាញ់ អ្នកមិនល្បួងខ្ញុំទេឬ នែដីវកៈ
ជាសំឡាញ់ អ្នកមិននាំខ្ញុំ (យកមក) ឲ្យដល់ពួកសត្រូវទេឬ ព្រោះថាកិច្ច

กาเย หิ ฉาย តាវមหาតោ កត្តុសង្ខ្យស្ស អឌ្ឍតេ-
ឌ្ឍសាខំ កត្តុសតាខំ នេវ ទិបទសង្ខោ ភវិស្សតិ
ន ចតុប្បាទសង្ខោ ន ពហុប្បទសង្ខោ ។ មា ភាយិ
មហាភ.ជ មា ភាយិ មហាភជ ន តំ នេវ វញ្ចេមិ
ន តំ នេវ បលម្ភាមិ ន តំ នេវ បច្ចត្ថិកោ-
នេមិ អភិក្កម មហាភជ អភិក្កម មហាភជ ឯតេ
មណ្ឌលមាឡេ បនីថ(๑) ឈាយន្តីតិ ។ អថខោ
ភជា មាតរោ អជាតសត្តុ វេទេហីបុត្តោ យាវតិកា
ជាតស្ស ភូមិ ជាតេន តត្ថ ជាតា បច្ចោភេមិត្វា
បនិតោ វ(๒) យេន មណ្ឌលមាឡស្ស ទ្វារំ តេនុ-
បសង្កមិ ឧបសង្កមិត្វា ជីវកំ កោមារភច្ចំ ឯតទ-
វោច កហំ បន សម្ម ជីវក ភគវាតិ ។ ឯសោ
មហាភជ ភគវា មជ្ឈិមំ ទេសំ ឯសិ្សាយ បុរត្ថា-
ភិមុខោ ឯសិង្ខោ បុរក្ខតោ តត្តុសង្ខ្យស្សតិ ។
អថខោ ភជា មាតរោ អជាតសត្តុ វេទេហីបុត្តោ

---

๑ ម. បីញ ๑๒ ន. ម. បត្តិកោ វ ។

សង្ឃជារាប់ដល់ម្ភៃ៉ះ ចំនួន ១២៥០ រូប ហេតុអ្វីក៏គ្មានសម្តែងកណ្តាស សម្តែងអ្នក សម្តែងតឹកតង់សោះ ។ ជីវកកោមារភច្ច ក្រាបបង្គំទូលថា បពិត្រមហាភន្ត សូមព្រះអង្គកុំខ្ជាបខ្ជឿយ បពិត្រមហាភន្ត សូមព្រះអង្គ កុំខ្ជាបខ្ជឿយ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនបញ្ឆោតព្រះអង្គទេ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនលួងព្រះអង្គទេ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិន(នាំយកព្រះអង្គមក)ឲ្យដល់ពួកសត្រូវទេ បពិត្រមហាភន្ត សូមព្រះអង្គស្តេចចូលទៅ បពិត្រមហាភន្ត សូមព្រះអង្គស្តេចចូលទៅ ន៎ុះន៎ បតីបតាំងក្បាយ ដែលគេអុជតាំងនៅកង់រោងមានសណ្ឋានមូល(១) ។ លំដាប់នោះ ព្រះបាទអជាតសត្តុវេទេហីបុត្តជាធំកង់ដែនមគធៈ ទ្រង់ស្តេចទៅដោយដំរីកំណាត់ត្រឹមទីដែលលូមបរដំរីទៅបាន ហើយក៏ទ្រង់ចុះពីដំរី ទ្រង់ស្តេចទៅដោយព្រះបាទ ចូលសំដៅទៅត្រង់ទ្វាររោងមានសណ្ឋានមូល លុះស្តេចចូលទៅដល់ហើយ ទ្រង់មានព្រះបន្ទូលដូច្នេះទៅនឹងជីវកកោមារភច្ចថា នែជីវកៈជាសំឡាញ់ ចុះព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណា ។ ជីវកកោមារភច្ច ក្រាបបង្គំទូលថា បពិត្រមហាភន្ត ន៎ុះន៎ព្រះមានព្រះភាគ ទ្រង់គង់ផ្អែកនឹងសសរកណ្តាល ឆ្ពោះព្រះភក្ត្រទៅទិសខាងកើត ខាងមុខភិក្ខុសង្ឃ ។ គ្រានោះ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង់ដែនមគធៈ

---

១ សាលាសម្រាប់អង្គុយ (អដ្ឋកថា ព្រះព្រហ្មជាលសូត្រ) ។

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ តុណ្ហីភូតំ តុណ្ហីភូតំ តំក្ខុ-សង្ឃំ អនុវិលោកេត្វា រហទមិវ វិប្បសន្នំ ឧឆានំ ឧឆា-ឌេសិ ឥមិនា មេ ឧបសមេន ឧទយភទ្ទោ(១) កុមារោ សមគ្គភតោ ហោតុ យេនេតរហិ ឧបសមេន តំក្ខុ-សង្ឃោ សមគ្គភតោតិ ។ អភមា ខោ តំ មហាភជ យថាមេមន្តិ ។ បិយោ មេ ភន្តេ ឧទយភទ្ទោ កុមារោ ឥមិនា មេ ភន្តេ ឧបសមេន ឧទយភទ្ទោ កុមារោ សមគ្គភតោ ហោតុ យេនេតរហិ ឧបសមេន តំក្ខុ-សង្ឃោ សមគ្គភតោតិ ។

(៧៣) អថខោ រាជា មាគធោ អជាតសត្តុ វេទេ-ហីបុត្តោ ភគវន្តំ អភិវាទេត្វា តំក្ខុសង្ឃស្ស អញ្ជលិំ ឧបនាមេត្វា(២) ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ ភគវន្តំ

---

១ ឧ. ឧទាយិភទ្ទោ ។ ២ ឧ. ម. បណាមេត្វា ។

ទ្រង់ស្តេចចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ទ្រង់បិតនៅក្នុងទីសមគួរ ។ លុះព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់បិតនៅក្នុងទីសមគួរហើយ ទើបទ្រង់ធ្វើឯព្រះនេត្រក្រឡេកទតទៅកិកុសង្ឃ ដែលអង្គុយនៅស្ងៀមចាំងអស់ ក៏ទ្រង់បន្ទឺនូវពាក្យដ៏ថ្លាស្អាត ដូចជាអន្ទង់ទឹកថា ឥឡូវនេះ កិកុសង្ឃប្រកបដោយសេចក្តីស្ងប់រម្ងាប់ណា សូមឲ្យពុទយកន្តុមារ ជាកូនរបស់អញប្រកបដោយសេចក្តីស្ងប់រម្ងាប់នេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រមហាពាជ ព្រះអង្គស្តេចមកដោយជាប់ចំពាក់ នឹងសេចក្តីស្រឡាញ់ផង ។ ព្រះបាទអជាតសត្តុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពុទយកន្តុមារជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កិកុសង្ឃ ប្រកបដោយសេចក្តីស្ងប់រម្ងាប់ណា សូមឲ្យពុទយកន្តុមារជាកូនរបស់ខ្ញុំព្រះអង្គ ប្រកបដោយសេចក្តីស្ងប់រម្ងាប់នេះផង ។

(៨៣) លំដាប់នោះ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងដែនមគធៈ ថ្វាយបង្គំព្រះមានព្រះភាគ ហើយប្រណម្យអញ្ជលី ចំពោះកិកុសង្ឃរួចហើយក៏គង់ក្នុងទីសមគួរ ។ លុះព្រះបាទអជាតសត្តុវេទេហីបុត្តជាធំក្នុងដែនមគធៈគង់ក្នុងទីសមគួរហើយ ទ្រង់ក្រាបបង្គំទូលព្រះមានព្រះភាគ

ឯតទភោច បុច្ឆយ្យាមហំ ភន្តេ ភគវន្តំ កញ្ចិទេវ ទេសំ
លេសមត្តំ សចេ មេ ភគវា ខិការំ ករោតិ បញ្ហស្ស
វេយ្យាករណាយាតិ ។ បុច្ឆ មហារាជ យថាការុណ្ឌំ ។
យថា ខុ ភោ ឥមានិ ភន្តេ បុថុសិប្បាយតនានិ
សេយ្យថីទំ ហត្ថារោហា អស្សារោហា រថិកា ធនុក្ខហា
ចេលកា ចលកា បិណ្ឌាយិកា ឧក្កា ភដបុត្តា
បក្ខន្ទិនោ មហានាគា សូរា ចម្មយោធិនោ ផាសុក-
បុត្តា អាឡារិកា កេវដ្ដា នហាបកា[1] សូនា មា-
លាការា រជកា បេសការា នឡការា កុម្ភការា
គណកា មុទ្ទិកា យានិ វា បនញ្ញានិបិ ឯវំគតានិ
បុថុសិប្បាយតនានិ តេ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញ-

---

1. នហាបិកាតិបិ ទិស្សតិ ។

ដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស បើព្រះមានព្រះភាគ ទ្រង់ធ្វើឧកាស ដើម្បីព្យាករណ៍ (ដោះ) ប្រស្នារបស់ខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គនឹងគប្បីចូលសួរនូវហេតុនីមួយ គ្រាន់តែជាលេសគ្រឿងអាងនឹងព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហាពាជ បើទ្រង់ប្រាថ្នាន៏ងសួរនូវប្រស្នាណា សូមទ្រង់សួរមកកុះ ។ ព្រះពាជទ្រង់សួរថា សូមទ្រង់ព្រះមេត្តាប្រោស ដូចជាសិល្បៈសម្រាប់បង្កើតផល មានប្រមាណច្រើនពាន់នេះ បានដល់សិល្បៈរបស់បុគ្គលនោះ ។ គឺសិល្បៈរបស់ពួកបុគ្គលអកកាន់ការខាងដំរី អកកាន់ការខាងសេះ អកកាន់ការខាងរថ ពួកខ្មាន់ធ្នូ ពួកអកកាន់ទង់ជ័យ (មុខ) ពួកអកចាត់ទ័ព ពួកអកបញ្ជូនសឹង ពួកព្រះរាជបុត្តអកពុះពារ (ចូលសង្គ្រាម) ពួកអកស៊ុះចូលទៅ កងសង្គ្រាម (អកយកអាសា) ពួកយោធាអកអង់អាច ពួកសេនាអកក្លៀវក្លា ពួកយោធាអកពាក់អាវក្រោះ ពួកកូននៃជនជាតិសៈ (ជាទីស្រឡាញ់របស់ចៅហ្វាយនាយ) ពួកអកធ្វើនំ ពួកជាងអកកោរកាត់ ពួកអកផ្តុតទឹក ពួកអកធ្វើអាហារ ពួកជាងក្រងផ្កា ពួកជាងជ្រលក់ ពួកជាងតម្បាញ ពួកជាងតម្បាញផែង ពួកជាងសូនឆ្នាំង ពួកអកបេះសេខនព្វន្ត ពួកអកបេះពប់ដោយម្រាមដៃទេ តុំនោះសោត សិល្បៈសម្រាប់បង្កើតផល មានប្រមាណច្រើនណាមួយដទៃទៀត ដែលមានរបៀបយ៉ាងនេះក្តី បុគ្គលពាន់នោះ រមែងចិញ្ចឹមជីវិតអាស្រ័យនូវផល

ដលំ ឧបជីវន្តិ តេ តេន អត្តានំ សុខេន្តិ បីណេន្តិ
មាតាបិតរោ សុខេន្តិ បីណេន្តិ បុត្តទារំ សុខេន្តិ បីណេន្តិ
មិត្តាមច្ចេ សុខេន្តិ បីណេន្តិ សមណព្រាហ្មណេសុ ទុទ្ធ-
ក្ខំ ឧក្កំសំ បតិដ្ឋបេន្តិ សោវគ្គិកំ សុខវិបាកំ សគ្គ-
សំវត្តនិកំ សក្កា នុ ខោ កន្តេ ឯវមេវ(១) និដ្ឋវ ធម្ម
សន្ទិដ្ឋិកំ សាមញ្ញដលំ បញ្ញបេតុន្តិ ។ អភិជានាសិ
ណោ ត្វំ មហារាជ ឥមំ បញ្ហំ អញ្ញេ សមណព្រាហ្មណេ
បុច្ឆិតាតិ ។ អភិជានាមហំ កន្តេ ឥមំ បញ្ហំ អញ្ញេ
សមណព្រាហ្មណេ បុច្ឆិតាតិ ។ យថា កថំ បន តេ

---

១ ម. ឯវមេវំ ។

របស់សិល្បៈ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន បុគ្គលគាំងនោះ រមែងធ្វើខ្លួន ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ (ដោយកម្លាំងកាយ កម្លាំងប្រាជ្ញា) រមែងធ្វើមាតាបិតា ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើបុត្រភរិយា ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើមិត្តអាមាត្យ ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងញុំាងទក្ខិណា. ទាន ដែលមានផលខ្ពស់ ជាទានគួរដល់នូវកិរិយាកើតក្នុងឋានសួគ៌ ជាទានមានផលនាំមកនូវសេចក្តីសុខ ជាទានញុំាងធម៌(១)គាំង ១០ ដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយល្អ ឲ្យតម្កល់ចំពោះសមណៈនិងព្រាហ្មណ៍គាំងឡាយ ដោយសិល្បៈនោះ បពិត្រព្រះអគ្គដ៏ចំរើន ព្រះអង្គអាចនឹងបញ្ញត្តនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬទេ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហាពាជ ក្រែងមហាពាជ បានសួរប្រស្នានេះ នឹងសមណព្រាហ្មណ៍គាំងឡាយដទៃជ្រាបច្បាស់ហើយឬ ។ ព្រះរាជាក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានសួរប្រស្នានេះនឹងសមណព្រាហ្មណ៍គាំងឡាយដទៃដឹងច្បាស់ហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហាពាជ ចុះសមណៈនិងព្រាហ្មណ៍គាំងឡាយនោះ ដោះស្រាយដោយប្រការ ដូចម្តេចខ្លះ បើ

---

១ ធម្មិកាំង ១០ ជាទិព្វគតិរូប សម្រេងក្នុង វេ ធ្យុ អាយុ វណ្ណៈ សុខ យស អធិបតី ។

មហាភាគ ព្យាករីសុ សពេ តេ អភរុ កាសស្សតំ ។ ឯ
ខោ មេ ភន្តេ ភរុ យត្តស្ស ភគវ ឯសំឡោ ភគវន្តរូបោ
ភតំ ។ តេនហិ មហាភាគ កាសស្សតំ ។

(៨៤) ឯកមិទាហំ ភន្តេ សមយំ យេន បុរាណោ
កស្សបោ តេនុបសង្កមិំ ឧបសង្កមិត្វា បុរាណេន កស្សប-
បេន សទ្ធិំ សម្មោទិំ សម្មោទនីយំ កថំ សារណីយំ
វីតិសារេត្វា ឯកមន្តំ និសីទិំ ឯកមន្តំ និសិន្នោ ខោ
អហំ ភន្តេ បុរាណំ កស្សបំ ឯតទវោចំ យថា ឥ ខោ
ឥមានិ ភោ កស្សប បុថុសិប្បាយតនានិ សេយ្យថីទំ
ហត្ថារោហា អស្សារោហា រថិកា ធនុក្កហា ចេលកា
ចលកា បិណ្ឌាយិកា ឧក្កា ភដបុត្តា បក្ខន្ទិនោ

មហាពាជ មិនទើសទាល់ទេ សូមមហាពាជឆ្ងើយមក ។ ព្រះពាជាក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគ ឬបុគ្គលដែលមានសភាពដូចជាព្រះមានព្រះភាគ គង់នៅក្នុងទីណា ទីនោះខុំព្រះអង្គមិនមានសេចក្តីទើសទាល់ទេ ។ ព្រះអង្គត្រាស់ថា បពិត្រមហាពាជ បើដូច្នោះ សូមមហាពាជ ទ្រង់មានព្រះពាជឧត្សាហ៍មកចុះ ។

(៤) ព្រះពាជាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងពាជគ្រឹះនេះ សម័យមួយ ខុំព្រះអង្គបានចូលទៅរកត្រួយ្លោះបួរណៈកស្សប លុះចូលទៅដល់ហើយ ក៏ពោលពាក្យពាក់ព័ន្ធសំណេះសំណាល ជាមួយនឹងត្រួយ្លោះបួរណៈកស្សប លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួរលឹក ឲ្យកើតសេចក្តីសិទ្ធស្កាលហើយ ក៏បានអង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខុំព្រះអង្គអង្គុយក្នុងទីសមគួរហើយ ក៏ផ្តើមពាក្យសួរដូច្នេះទៅនឹងត្រួយ្លោះបួរណៈកស្សបថា បពិត្រលោកកស្សប ដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ គឺសិល្បៈរបស់ពួកបុគ្គលអ្នកជិះដំរី(១) អ្នកជិះសេះ(២) អ្នកគាន់ការខាងរថ ពួកខាន់ធ ពួកអ្នកគាន់ទង់ជ័យ (មុខ) ពួកអ្នកចាត់ទ័ព ពួកអ្នកបញ្ជាន ស្បៀង ពួកព្រះពាជបុត្តអ្នកពុះពារ (លុកចូលកងសង្គ្រាម) ពួកអ្នកសុរ

១-២ អដ្ឋកថា ថា អ្នកថែរក្សាជើរសេះ កំពង់បញ្ចូលក្នុងជំនពួកនេះទាំងអស់ ។

មហានាគា សុភ ធម្មយោធនោ ឆាសកបុត្តា អានន្ទរ-

ត្ថា តម្ពត្ថា ឧហាមត្ថា សុធា មាលាភារ ផ្ទត្ថា

បេសការ ឆលត្ថារ កុម្ភត្ថារ កណត្ថា មុទ្ធិត្ថា

យានំ វា បនញ្ញេនំ វា រូបិតានំ បុថុសិប្បាយតនានំ តេ

ដំដ្ឋេ វ ឆម្មេ សន្ថដ្ឋកំ សិប្បដលំ ឆុបដីវត្តំ តេ តេន

អត្តានំ សុខេត្តំ បរិណាត្តំ មាតាបិតរេ សុខេត្តំ បរិណាត្តំ

បុត្តទារំ សុខេត្តំ បរិណាត្តំ មិត្តាមច្ចេ សុខេត្តំ បរិណាត្តំ

សមណព្រាហ្មណេសុ ឧទកំ្តកំ ឧក្កំ្តលំ បតិដ្ឋបេត្តំ

សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ សក្កា នុ ខោ

តេ តាសប្បេ រូបាមេ ធំដ្ឋេ វ ឆម្មេ សន្ថដ្ឋកំ សាមញ-

ចូលសម្រុកក្នុងសង្គ្រាម ពួកយោធាអ្នកអង់អាច ពួកសេនាអ្នកក្លៀវក្លា ពួកយោធាអ្នកពាក់គ្រឿងក្រោះ ពួកកូននៃជនជាទាស: (ជាទីស្រឡាញ់របស់ចៅហ្វាយនាយ) ពួកអ្នកធ្វើនំ ពួកជាងអ្នកកោរកាត់ ពួកអ្នកផ្តទឹកប្រឹ ពួកអ្នកធ្វើអាហារ ពួកជាងក្រងផ្កា ពួកជាងជ្រលក់ ពួកជាងតម្បាញ ពួកជាងត្បាញផែង ពួកសូនធាំង ពួកអ្នកចេះលេខនព្វន្ត ពួកអ្នកចេះគិតដោយគ្រាមដៃទេ ពុំនោះសោត សិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនឯណានីមួយដទៃទៀត ដែលមានបែបយ៉ាងនេះ បុគ្គលទាំងនោះ រមែងចិញ្ចឹមជីវិតអាស្រ័យនូវផលរបស់សិល្បៈ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន បុគ្គលទាំងនោះ រមែងធ្វើខ្លួនឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើមាតាបិតា ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើបុត្រកិយោឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើមិត្តអាមាត្យឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងញុំាងទក្ខិណាទានដែលមានផលខ្ពស់ ជាទានគួរដល់កិរិយាកើតក្នុងស្ថានសួគ៌ ជាទានមានផលនាំមកនូវសេចក្តីសុខ ជាទានញុំាងធម៌ទាំង ១០ ដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយល្អ ឲ្យតម្កល់នៅក្នុងសមណៈនឹងព្រាហ្មណ៍ទាំងឡាយ ដោយសិល្បៈនោះ បពិត្រលោកកស្សបដ៏ចំរើន លោកអាចនឹងបញ្ញត្តនូវផលនៃសមណប្បដិបត្តិ(១) ដែលឃើញច្បាស់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈ

---

១ សាមញ្ញផល ធម៌ផលផ្នែសឬជាអានិសង្សនៃអ្នកបួសក្នុងសាសនា ។

ដលំ បញ្ចវេត្តុដ្ឋំ ឃំ វុត្តេ កន្តេ ប្បវណោ កាសប្បគោ មំ
ឃតនភេទ កាភេគោ[1] ខោ មហាភដ កាយេគោ ជិន្ទ-
គោ ជេដ្ឋាបយគោ បចគោ បចាបយគោ សោចយគោ
សោចាបយគោ កិលមយគោ កិលមាបយគោ ជន្ទគោ
ជន្ទាបយគោ ចាណាមតិចាបយគោ[2] អជិន្ទំ អាជិយ-
គោ សន្ទំ ជិន្ទគោ ជិល្ហាបំ មារគោ ឃកាគារិកំ កាភេ-
គោ បរិបន្ថេ តិដ្ឋគោ បរទារំ គច្ឆគោ មុសា កណាគោ
ការគោ ន ការិយតិ ចាបំ ខុរបរិយន្តេន ចេបំ ចក្កេន
យោ សមិសប្ប បឋវិយា ចាណោ ឃកំ មំសខលំ ឃកំ
មំសបុញ្ជំ ការេយ្យ ជត្តិ តគោជិដ្ឋាធំ ចាបំ ជត្តិ ចាបស្ស
អាកគោ ជក្កំណាភោបំ កង្កាយ តិរំ កច្ចេយ្យ ហាជន្តោ

ក ខ. ការគោ ។ ២ ខ. ចាបយគោ សោចយគោ កិលមយគោ ជិន្ទគោ ជិន្ទាបយគោ ចាណំ អតិមាបយគោ ។ ម. ចាណមតិចាបយគោ ។

នោះឬទេដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គសួរយ៉ាងនេះ
ហើយ គ្រូឈ្មោះបូរណកស្សប ធ្វើយដូច្នេះទទឹងខ្ញុំព្រះអង្គថា បពិត្រមហាជ
បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ កាត់(នូវអវយវៈមានដៃ
ជាដើម) របស់អ្នកដទៃដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ
ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើអ្នកដទៃឲ្យសោកសៅដោយ
ខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេសោកសៅ ធ្វើអ្នកដទៃឲ្យលំបាកដោយ
ខ្លួនឯងឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេលំបាក អន្ទះអន្ទែងដោយខ្លួនឯង ឬធ្វើគេឲ្យ
អន្ទះអន្ទែង សម្ងាប់សត្វដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្ងាប់ កាន់យកនូវ
ទ្រព្យដែលគេមិនបានឲ្យ កាត់នូវទីគំ(នៃផ្ទះ)ប្លន់នូវពួកអ្នកស្រុក ឆក់យក
ទ្រព្យតែផ្ទះ ១ ឈរចាំកែវផ្លូវ (ដើម្បីដណ្តើមយកទ្រព្យ) លួចប្រពន្ធនៃ
បុគ្គលដទៃ ពោលពាក្យកុហក ឈ្មោះថា មិនបានធ្វើបាបទេ មួយទៀត
បើបុគ្គលណា ធ្វើនូវសត្វទាំងឡាយលើផែនដីនេះ ឲ្យមានគំនរសាច់តែមួយ
ឲ្យមានពំនូកនៃសាច់តែមួយ ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុតជូជាកាំបិត
កោរ ចាប់ដែលមានអំពើនោះជាហេតុមិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ
អំពើបាបក៏មិនឲ្យផល (ដល់បុគ្គលនោះឡើយ) ទោះបីបុគ្គលឆ្លងទៅកាន់
ត្រើយខាងស្តាំនៃទន្លេគង្គាហើយក៏ដោយ សម្ងាប់សត្វដោយខ្លួនឯង ឬប្រើអ្នក

ឃានតោឆ្ពោ ជិវ្ហាឆ្ពោ តេជាធាតោឆ្ពោ បឋវីឆ្ពោ បថាធាតោឆ្ពោ[1]
ឯត្ថ តតោ ជិវ្ហាយ ចាបំ ឯត្ថ ចាបស្ស អាកាសោ ទុត្តរញ្ចេ-
បំ កដ្ឋាយ តីរំ កត្តេយ្យ ឧទកាឆ្ពោ ឧទាធាតោឆ្ពោ[2] យាគូឆ្ពោ
យាធាតោឆ្ពោ ឯត្ថ តតោ ជិវ្ហាយ ចាបំ ឯត្ថ ចាបស្ស
អាកាសោ ទាតេន ទមេន សំយមេន សច្ចវាតេន[3] ឯត្ថ
តតោ ជិវ្ហាយ ចាបំ ឯត្ថ ចាបស្ស អាកាសោតំ ឥត្ថំ ខោ
មេ ភន្តេ ឃរណោ ភាសន្តោ សង្ខិដ្ឋិកំ សាមញ្ញលំ
បុដ្ឋោ សមាណោ អភិរយំ ព្យាការំ សេយ្យថាបំ ភន្តេ
អម្ពំ វា បុដ្ឋោ លពុជំ ព្យាការេយ្យ លពុជំ វា បុដ្ឋោ
អម្ពំ ព្យាការេយ្យ ឯវមេវ ខោ មេ ភន្តេ ឃរណោ ភាសន្ត-
ោ សង្ខិដ្ឋិកំ សាមញ្ញលំ បុដ្ឋោ សមាណោ អតិរយំ

---

១ ឧ. ជាធាឆ្ពោ ។ ២ ឧ. ម. ភាធាឆ្ពោ ។ ៣ ឧ. ម. សច្ចវាឆ្ឆេន ។

ដទៃឲ្យសម្លាប់ កាត់ (នូវអវយវៈមានដៃជាដើម) ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបៀតបៀន ចាបដែលមានអំពើនោះជាហេតុ មិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ អំពើចាបក៏មិនឲ្យផល (ដល់បុគ្គលនោះឡើយ) ទោះបីបុគ្គលធ្វើនៅកាន់គ្រឿងខាងធ្មេញនៃទន្លេគង្គាហើយឲ្យទានដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យឲ្យ បូជាដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុ មិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ អំពើបុណ្យមិនឲ្យផល (ដល់បុគ្គលនោះឡើយ) បុគ្គលធ្វើគុសលដោយឲ្យទាន ដោយទូន្មានទូវត្ថ្រទ្វិយ ដោយសង្រ្គមកាយវាចា ដោយពោលពាក្យសច្ចៈ បុណ្យដែលមានអំពើនោះជាហេតុ មិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ អំពើបុណ្យមិនឲ្យផល (ដល់បុគ្គលនោះឡើយ) បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះបូរណកស្សប កាលដែលទ្រង់ព្រះអង្គ សួរពីផលសមណប្បដិបត្តិដែលឃើញច្បាស់ ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយ ដោយអាកិរិយាទ (ពោលឃាត់អំពើបុណ្យចាប) បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ បែរជាច្រាបទូរដើមខ្នុរសម្ងួតវិញ ឬគេសួរពីដើមខ្នុរសម្ងួត បែរជាច្រាបទូរដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះបូរណកស្សប កាលទ្រង់ព្រះអង្គសួរពីផលនៃសមណប្បដិបត្តិដែល

ព្យាកាសិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ នុ ខោ មាទិសោ សមណំ វា ព្រហ្មណំ វា វិដតេ វាសន្តំ អបសាទេតព្ពំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ ប្បរាសស្ស កាសប្បស្ស កាសិតំ នេវ អភិនន្ទិំ នប្ប-ដិក្កោសិំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា អនត្តមនោ អនត្តមនភាវំ អនុដ្ឋាយេត្វា តមេវ ភវំ អនុក្កណ្ឋោ អនិក្កុជ្ឈន្តោ ឧដ្ឋាយាសនា បក្កាមិំ ។

(៤៥) ឯកមិទាហំ ភន្តេ សមយំ យេន មក្ខលិ គោសាលោ តេនុបសង្កមិំ ឧបសង្កមិត្វា មក្ខលិំ គោសាលេន[1] សទ្ធិំ សម្មោទិំ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិំ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ មក្ខលិំ គោសាលំ ឯតទវោចំ យថា នុ ខោ ឥមាសិ គោ គោសាល បុថុសិប្បាយតនានំ ។ បេ ។ សក្កា នុ ខោ គោសាល ឥធមេវ ទិដ្ឋេ ។

---

១ ម ម្ហ លិគោសាលេន ។

ឃើញច្បាស់ដោយខ្លួនឯងហើយ បែរជាដោះស្រាយ ដោយអភិយោគទៅវិញ ក៏ដូច្នោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិតដូច្នេះថា បុគ្គលប្រហែលដូចជាអញ មិនសមបើទៅរាប់អានសមណៈ ឬព្រាហ្មណ៍ អ្នកនៅអាស្រ័យកន្លែងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម នូវកាសិតរបស់គ្រូឈ្មោះបូរណកស្សបឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម មានសេចក្តីតូចចិត្ត តែមិនបានបញ្ចេញវាចាសំដែងនូវសេចក្តីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយក៏ក្រោកចាកអាសនៈចៀសចេញទៅ ។

(៤៩) បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅកាន់គ្រូឈ្មោះមក្ខលិគោសាល លុះចូលទៅដល់ហើយក៏ពោលពាក្យពាក់ព័ន្ធសំណេះសំណាល ជាមួយនឹងគ្រូឈ្មោះមក្ខលិគោសាល លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួរលឹកលួមឲ្យកើតសេចក្តីសិនស្មាលហើយ ក៏បានអង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ក៏ផ្តើមពាក្យសួរដូច្នេះទៅនឹងគ្រូឈ្មោះមក្ខលិគោសាលថា បពិត្រលោកគោសាលដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ។ បេ ។ បពិត្រលោកគោសាល

ឯម្ហេ សន្ធិដ្ឋកំ សាមញ្ញផលំ បញ្ញាបេតុន្តិ វា វុត្តេ ភគ្គេ
មក្ខលិ គោសាលោ មំ វតនភេច ឧត្តំ មហាភជ ហេតុ
ឧត្តំ បច្ចយោ សត្តានំ សំកិលេសាយ អហេតូ អប្បច្ច-
យោ សត្តា សំកិលិស្សន្តិ ឧត្តំ ហេតុ ឧត្តំ បច្ចយោ
សត្តានំ វិសុទ្ធិយា អហេតូ អប្បច្ចយោ សត្តា វិសុជ្ឈន្តិ
ឧត្តំ អត្តការេ ឧត្តំ បរការេ ឧត្តំ បុរិសការេ ឧត្តំ ពលំ
ឧត្តំ វីរិយំ ឧត្តំ បុរិសថាមោ ឧត្តំ បុរិសបរក្កមោ សព្ពេ

ដ៏ចំរើន លោកអាចនឹងបញ្ញត្តនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ បពិត្រព្រះអគ្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះមក្ខលិគោសាល បានពោលភាសុដូច្នេះមកនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ ហេតុបច្ច័យនាំឲ្យសៅហ្មង ដល់សត្វទាំងឡាយមិនមានទេ សត្វទាំងឡាយរមែងសៅហ្មងដោយឥតហេតុ ឥតបច្ច័យ ហេតុបច្ច័យនាំឲ្យបរិសុទ្ធដល់សត្វទាំងឡាយមិនមានឡើយ សត្វទាំងឡាយ រមែងបរិសុទ្ធដោយឥតហេតុ ឥតបច្ច័យ អំពើរបស់ខ្លួន(១)ក៏មិនមាន អំពើរបស់អ្នកដទៃ(២) ក៏មិនមាន អំពើរបស់បុរស(៣)ក៏មិនមាន កម្លាំងក៏មិនមាន ព្យាយាមក៏មិនមាន កម្លាំងរបស់បុរសក៏មិនមាន សេចក្តីសង្វាតរបស់បុរស(៤)ក៏មិនមាន

---

១ អត្ថកថា ថា សត្វទាំងឡាយបានអត្តភាពជាទេវតាក្តី ជាមារក្តី ជាព្រហ្មក្តី ជាសាវកពោធិក្តី ជាបច្ចេកពោធិក្តី ជាសព្វញ្ញុតញ្ញាណក្តី ដោយកុសលកម្មដែលខ្លួនបានធ្វើ ឈ្មោះថា អំពើរបស់ខ្លួន ។ ២ សត្វទាំងឡាយបានគួរនូវគុណាធិមានរួបល្អក្នុងអត្តភាពជាមនុស្សរហូតដល់ព្រះអរហត្ត ជាទីបំផុត ក៏ព្រោះអាស្រ័យនឹងពាក្យទូន្មានប្រៀនប្រដៅរបស់អ្នកដទៃឈ្មោះថា អំពើរបស់អ្នកដទៃ ។ ៣ សត្វទាំងឡាយបានសម្បត្តិធំប្រសើរ ដោយអំពើនឹងព្យាយាមរបស់បុរស ឈ្មោះថា អំពើរបស់បុរស ។ ៤ ពាក្យទាំង ៥ នេះ ជាពាក្យផ្ទាស់ប្តូរគ្នា មានសេចក្តីដូចគ្នាតែម្យ៉ាង។

សត្តា សព្ពេ ចាណា សព្ពេ ភូតា សព្ពេ ជីវា អវសា
អពលា អវីរិយា និយតិសង្គតិភាវបរិណតា ឆស្វេវ-
ភិជាតីសុ សុខទុក្ខំ ปฏิสංවේදේන්ති(๑) បដិសំវេទេន្តិ ពុទ្ធស
ទ្ធោ បដិអាដ្ឋ មហាកប្បិ(๒) យោនិប្បមុខសតស-
ហស្សានំ សដ្ឋិ ច សតានិ ច សតានំ(๓) បញ្ច.
ច កម្មុនោ សតានិ បញ្ច ច កម្មានិ តីណិ ច
កម្មានិ កម្មេ ច ឧបឌ្ឍកម្មេ(๔) ច ទ្វដ្ឋិបដិបទា

---

๑ ម. ឆស្វេវាភិជាតីសុ សុខទុក្ខំ ។ ๒ ម. ប. មហាកប្បិនោ បាហេ ន ទិស្សតិ ។
๓ ម. សដ្ឋិញ្ច សតានិ ឆ ច សតានិ ។ ๔ ម. អឌ្ឍកម្មេ ។

សត្វទាំងអស់ (មានសត្វទុដ្ឋ គោ លា ជាដើម) ចាណៈទាំងអស់(១) កូតទាំងអស់ (មានសត្វកើតក្នុងស្រោមស៊ុតជាដើម) ដីវៈគឺធញ្ញជាតិទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម(ក្នុងការធ្វើឲ្យសៅហ្មងឬបរិសុទ្ធ) មានសេចក្តីប្រែប្រួលដោយនិយតិនិងសង្គតិ នៃសភាវៈ(២) តាំងនៅក្នុងអភិជាតិទាំង ៦ ហើយវាមិនទទួលសុខនិងទុក្ខ បពិត្រមហាពដ្ឋ ឯកំណើតដែលជាប្រធាន(៣) មានចំនួន ១ លាន ៤ សែន ៦ ពាន់ ៦ រយ ទាំងនេះក្តី កម្មទាំង ៥០០ ក្តី កម្មទាំង ៥ ក្តី កម្មទាំង ៣ ក្តី កម្មគឺកាយកម្មនិងវចីកម្មក្តី កម្មពាក់កណ្តាល គឺមនោកម្មក្តី បដិបទាទាំង ៦២ ក្តី

---

១ សត្វដែលមានឥន្ទ្រិយ ១ គឺរូបនិងជីវិតិន្ទ្រិយ ជានដែលអស្សញ្ញីសត្វ សត្វដែលមានឥន្ទ្រិយ ២ គឺឥត្ថិន្ទ្រិយ ១ សោតិន្ទ្រិយ ១ ជានដែលប៉ូចព្រហ្ម ១៤ ជាន់ រៀរលែងអស្សញ្ញីព្រហ្មលោកទេ ។ ២ សេចក្តីដិតស្អិតមិនបែកធ្លាយ ប្រៀបដូចខ្សែកែវមែណី ដែលមិនប្រេះធារៈល្មោះថា ឥយតិ ។ ការព្រាប់រង្គាត់ទៅក្នុងអភិជាតិទាំង ៦ ឈ្មោះថា សង្គតិ ។ ធម្មតាដែលកើតឡើងជាមួយ ។ គ្នា ឈ្មោះថា សភាវៈ ប្រៀបដូចបងប្អូនដែលស្រួចឯង ផ្ទៃក្តៅមានសណ្តានមូលដោយខ្លួនឯង សត្វច្រើនបក្សីទាំងពួងមានរូបរាងវិចិត្រផ្សេង ។ ដោយធម្មតាឯង យ៉ាងណាមិញ លោកទាំងអស់មានសេចក្តីប្រែប្រួលទៅជាដូច្នោះ ។ មិនបាច់អាស្រ័យហេតុបច្ច័យឡើយ ប្រៀបដូចបងប្អូនដើម យ៉ាងនោះឯង ឈ្មោះថា សភាវៈ ។ ៣ មានកំណើត មនុស្ស តិរច្ឆាន ក្សត្រិយ៍ នឹងព្រាហ្មណ៍ជាដើម ។

ទូដ្ឋន្តរកប្ប ឆឡភិជាតិយោ អដ្ឋបុរិសភូមិយោ ឯកូន-

បញ្ញាស អាជីវកសតេ ឯកូនបញ្ញាស បរិព្វាជកសតេ

ឯកូនបញ្ញាស ឆកាសសតេ[1] រីសេ នត្ថិយសតេ តឹ-

សេ និរយេសតេ ឆឌ្ឌេសរជោជាតុយោ សត្តសញ្ញីភវា ស-

ត្តអសញ្ញីភវា សត្តនិកណ្ឋីភវា សត្តឆេកា សត្តមនុស្សា

សត្តបិសាចា[2] សត្តសរ សត្តបវុដា សត្តបវុដសតានិ

---

๑ ឧ ម. នាគារាសសតេ ។ ๒ ខ. សត្តបេសាច ។

អន្តរកប្ប(១)ទាំង៦៤ក្តី អកិជាតិ(២)ទាំង ៦ បុរិសភូមិ(៣)ទាំង ៨ ពួកអាជីវកៈទាំង ១៤៩ ពួកបរិព្វាជកទាំង ១៤៩ លំនៅនៃនាគទាំង ១៤៩ ឥន្ទ្រិយទាំង ១២០ នរកទាំង ១៣០ ជាតុដែលប្រកបដោយធូលី (មានខ្នងដៃខ្នងដើរជាដើម) ទាំង៣៦ពួក គតិនៃសត្វដែលមានសញ្ញា(៤)ទាំង៧ ពួកគតិ (នៃធញ្ញជាតិ) ដែលគ្មានសញ្ញា(៥)ទាំង៧ ពួកគតិនៃជាតិដែលដុះអំពីថ្នាំង (មានអំរៅជាដើម) ទាំង៧ ពួកទេវតាទាំង៧ ពួកមនុស្សទាំង៧ ពួកបិសាចទាំង ៧ ស្រះទាំង៧ រអាងភ្នំទាំង៧ រអាងភ្នំទាំង៧០

---

១ អដ្ឋកថា ថា ក្នុងមហាកប្ប ១ មានអន្តរកប្ប ៦៤ តែគ្រូឈ្មោះមក្ខលិគោសាលមិនដឹងក្តីប្លោះទេ បានជាពោលថា ៦២ ។ ២ ឯអកិជាតិទាំង ៦ នោះ គឺកណ្ហាភិជាតិ (ជាតិខ្មៅ) បានដល់ព្រានម្រឹគព្រានបក្សីជាដើម ១ នីលាភិជាតិ (ជាតិខៀវ) បានដល់ភិក្ខុដែលបួសក្នុងព្រះពុទ្ធសាសនា ១ លោហិតាភិជាតិ (ជាតិក្រហម) បានដល់ពួកនិគ្រណ្ឋ ១ ហលិទ្ទកិជាតិ (ជាតិលឿងដូចរមៀត) បានដល់ពួកអចេលកសាវក ១ សុក្កាភិជាតិ (ជាតិស) បានដល់ពួកអាជីវក ១ បរមសុក្កាភិជាតិ (ជាតិសណោស់) បានដល់ជនជាតនុគោត្រ តឹងរបួតគោត្រជាដើម ១ ។ ៣ ឯបុរិសភូមិទាំង ៨ នោះ គឺមនុភូមិ (កាលដែលនៅល្ងង់ខ្លៅ) បានដល់ការដែលទើបប្រសូតមកបាន ៧ ថ្ងៃនៅល្ងង់វង្វេង ១ ទិដ្ឋាភូមិ (កាលដែលមានល្បែង) បានដល់ការដែលមកអំពីទុគ្គតិយំស្រែកប្រើន ឬការដែលមកពីសុគតិ រលឹកឃើញសុគតិហើយសើចរីករាយសប្បាយប្រើន ១ បឋវីមិសភូមិ (កាលទើបរៀនដើរ) បានដល់ការដែលទើបចេះកាន់ដៃអាតាបំតារៀនដើរ ១ ខដុគតភូមិ (កាលដែលដើរត្រង់បាន) បានដល់ការដែលចេះដើររឹងប៉ឹងហើយ ១ សេក្ខភូមិ (កាលដែលសិក្សាសិល្បៈ) ១ សមណភូមិ (កាលដែលបួស) ១ ជិនភូមិ (កាលដែលរៀនសិល្បៈអំពីសំណាក់អាចារ្យចេះដឹងស្រេចហើយ) ១ បុគ្គភូមិ (កាលបួសហើយព្រាប់ទៅបំណ្ងបាត ឬប្រតិបត្តិធម៌ ឬកាសំគ្រាំគ្រា) ១ ។ ៤ សត្វដែលមានសញ្ញា ៧ នោះ គឺខ្ញី ១ គោ ១ លា ១ ពពែ ១ សត្វបិញ្ចឹម ១ ម្រឹគ ១ ក្របី ១ ។ ៥ ធញ្ញជាតិ ៧ នោះ គឺស្រូវសាលី ១ ស្រូវខ្លាយ ១ ស្រូវដំណើប ១ ស្រែង ១ កន្ទុយដំរី ១ ស្វាយ ១ តែលលាក ១ ។

សត្តបថាតា សត្តបថាតសតានិ សត្តសុបិនា សត្តសុបិ-
នសតានិ ចុល្លាសីតិមហាកប្បានោ[1] សតសហស្សានិ
យានិ ពាលេ ច បណ្ឌិតេ ច សង្ធាវិត្វា សំសរិត្វា
ទុក្ខស្សន្តំ ករិស្សន្តិ តត្ថ នត្ថិ ឥមិនាហំ សីលេន វា
វត្តេន វា តបេន វា ព្រហ្មចរិយេន វា អបរិបក្កំ វា
កម្មំ បរិចាចេស្សាមិ បរិបក្កំ វា កម្មំ ផុស្សា
ផុស្សា[2] ព្យន្តិករិស្សាមីតិ ហេវំ នត្ថិ នោ ណាមិតេ
សុខទុក្ខេ បរិយន្តកតេ សំសារេ នត្ថិ ហានវឌ្ឍនេ[3]
នត្ថិ ឧក្កំសាវក្កំសេ សេយ្យថាបិ នាម សុត្តគុឡេ
ខិត្តេ និព្ពេឋិយមានមេវ បលេតិ ឯវមេវ ពាលេ ច បណ្ឌិ-
តេ ច សង្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តីតិ ឥត្ថំ

---

១ ខ. ចុល្លាសីតិមហាកប្បិនោ ។ ២ ខ. ម. ផុស្ស ផុស្ស ។ ៣ ខ. ម. ហាយនវឌ្ឍនេ ។

ជ្រោះធំទាំង ៧ ជ្រោះតូចទាំង ៧០០ សុបិនធំទាំង ៧ សុបិនតូចទាំង ៧០០ ជនពាលក្តី ជនជាបណ្ឌិតក្តី អន្លោលទៅ គ្រាច់រង្គាត់ទៅ (ក្នុងវដ្ដសំសារ) អស់កាលចំនួន ៨ លានចុល្លមហាកប្បហើយទើងធ្វើនូវទីបំផុតនៃទុក្ខបាន បុគ្គលកំណត់ទុកថា អាត្មាអញនឹងញ៉ាំងកម្មដែលមិនទាន់ចាស់ឲ្យចាស់ផង អាត្មាអញបានពាល់ត្រូវរឿយ ។ នូវកម្មដែលចាស់ស្រាប់ហើយ ។ ផ្តើឲ្យអស់ទៅផង ដោយសីលនេះក្តី ដោយវត្តនេះក្តី ដោយតបៈនេះក្តី ដោយព្រហ្មចរិយៈនេះក្តី កុងកប្បទាំងឡាយនោះ មិនមានឡើយ សេចក្តីសុខទុក្ខដែលធ្វើឲ្យមានទីបំផុត ដូចគេវាល់របស់ (ឲ្យអស់ទៅ) ដោយទោណៈ មិនមានក្នុងសំសារវដ្ដ ដោយប្រការយ៉ាងនេះឡើយ សេចក្តីសាបសូន្យ (នៃសំសារបស់ជនជាបណ្ឌិត) ទើងសេចក្តីចំរើន (នៃសំសារបស់ជនពាល) មិនមានឡើយ សេចក្តីលូតលាស់ឡើងទើងសេចក្តីវេចរិល មិនមានឡើយ ប្រៀបដូចរមូរនៃអម្បោះ ដែលគេចោះចាលទៅ រសាយអស់ (ត្រឹមតែកំណត់អម្បោះប៉ុណ្ណោះ) យ៉ាងណាមិញ ជនពាលក្តី ជនជាបណ្ឌិតក្តី ដែលអន្លោលទៅ គ្រាច់រង្គាត់ទៅ (ក្នុងសំសារ) (អស់កំណត់នេះហើយ) ទើងធ្វើនូវទីបំផុតនៃទុក្ខបានដូច្នោះឯង បពិត្រ

ខោ មេ កន្តេ មក្ខលិ គោសាលោ សង្ឃិដ្ឋកំ សាមញ្ញ-
ផលំ បុដ្ឋោ សមានោ សំសារសុទ្ធិំ ព្យាកាសិ សេយ្យ-
ថាបិ កន្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ
វា បុដ្ឋោ អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ[1] កន្តេ មក្ខ-
លិ គោសាលោ សង្ឃិដ្ឋកំ សាមញ្ញផលំ បុដ្ឋោ សមានោ
សំសារសុទ្ធិំ ព្យាកាសិ តស្ស មយ្ហំ កន្តេ ឯតទហោសិ
កថំ ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា
វិជិតេ វសន្តំ អបសាទេតព្ពំ មញ្ញេយ្យាតិ សោ ខោ
អហំ កន្តេ មក្ខលិស្ស គោសាលស្ស ភាសិតំ នេវ
អភិនន្ទិំ ន បដិក្កោសិំ អនភិនន្ទិត្វា អបដិក្កោសិត្វា
អនត្តមនោ អនត្តមនភាវំ អដ្ឋបេត្វា តមេវ ភវំ
អង្គណមាគោ អដ្ឋក្កុដ្ឋេ[2] ឧដ្ឋាយាសនា បក្កាមិំ ។

---

១ ម. មេតំ បទំ ន ទិស្សតិ ។ ២ ម. អដ្ឋក្កុដ្ឋេ ។ ម. អដ្ឋក្កុជេ ។

ព្រះអង្គដ៏ចំរើន គ្រូឈ្មោះមក្ខលិគោសាល កាលខ្ញុំព្រះអង្គសួរកេផលនៃ
សមណប្បដិបត្តិដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ
ក៏បែរជាដោះស្រាយ នូវសេចក្តីបរិសុទ្ធិនៃសំសារៈវិញ បពិត្រព្រះអង្គ
ដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ ក៏បែរជាច្រាច់នូវ
ដើមខ្នុរសម្ងូវិញ ឬគេសួរពីដើមខ្នុរសម្ង បែរជាច្រាច់នូវដើមស្វាយវិញ
បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះមក្ខលិគោសាល កាលដែលខ្ញុំព្រះអង្គ
សួរកេផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ហើយបែរ
ជាដោះស្រាយនូវសេចក្តីបរិសុទ្ធិ នៃសំសារៈវិញ ដូច្នេះឯង បពិត្រ
ព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិត ដូច្នេះថា បុគ្គលប្រហែល
អញ មិនសមបើទៅពប់អានសមណៈឬព្រាហ្មណ៍ អ្នកនៅអាស្រ័យក្នុង
ដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ
មិនបានត្រេកអរ មិនបានឃាត់ហាមនូវភាសិត របស់គ្រូឈ្មោះមក្ខលិ-
គោសាលឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម ក៏មាន
សេចក្តីតូចចិត្ត តែមិនបានបញ្ចេញវាចា សំដែងនូវសេចក្តីតូចចិត្ត មិន
បានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយក៏ក្រោក
ចាកអាសនៈ ចៀសចេញទៅ ។

(៨៦) ឯកមិធាហំ ភន្តេ សមយំ យេន អដ្ឋិតោ កោសកម្ពលោ[1] តេនុបសង្កមិំ ឧបសង្កមិត្វា អដ្ឋិតេន កោសកម្ពលេន[2] សទ្ធិំ សម្មោទិំ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិំ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ អដ្ឋិតំ កោសកម្ពលំ ឯតទវោចំ យថា ន្វ ខោ ឥមានិ កោ អដ្ឋិត បុថុសិប្បាយ. តនានិ ។ បេ ។ សក្កា ន្វ ខោ កោ អដ្ឋិត ឯវមេវ ឥធេវ វ ជម្ម សន្ទិដ្ឋិកំ សាមញ្ញផលំ បញាបេ. តុន្តិ ឯវំ វុត្តេ ភន្តេ អដ្ឋិតោ កោសកម្ពលោ មំ ឯតទវោច ឆត្តំ មហារាជ និក្ខ ឆត្តំ យានំ ឆត្តំ ហុតំ ឆត្តំ សុកតឧក្កាជាំ កម្មានំ ផលំ វិបាកោ

---

១ ម. កេសកម្ពលោ ។ ២ ម. កេសកម្ពលេន ។

(៤៦) បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកគ្រូឈ្មោះអជិតកេសកម្ពល លុះចូលទៅដល់ហើយ ក៏ពោលពាក្យពាក់ព័ន្ធសំណេះសំណាល ជាមួយនឹងគ្រូឈ្មោះអជិតកេសកម្ពល លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួរលើកល្អមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏បានអង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ក៏ធ្វើមពាក្យសួរដូច្នេះទៅនឹងគ្រូឈ្មោះអជិតកេសកម្ពលថា បពិត្រលោកអជិតដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណប្រើនទាំងនេះ ។បេ។ បពិត្រលោកអជិតដ៏ចំរើន លោកអ្នកអាចនឹងបញ្ញត្តនូវផលនៃសមណៈបានដែរឬទេ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើ កាលដែលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះអជិតកេសកម្ពល ក៏បានពោលពាក្យដូច្នេះ នឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច[1] មិនមានផល ផលនឹងវិបាក[2]នៃកម្មដែលបុគ្គលធ្វើល្អនឹងធ្វើ

---

១ អដ្ឋកថា ថា គ្រឿងសក្ការៈដែលគេធ្វើដល់ភ្ញៀវ ។ ២ ផលដែលហូរមកលើសលុបហៅថាផល ផលដែលប្រហែលនឹងកម្ម ដែលបុគ្គលធ្វើហើយ ហៅថា វិបាក ។

ឧត្តំ អយំ លោកោ ឧត្តំ បរលោកោ[๑] ឧត្តំ មាតា ឧត្តំ បិតា ឧត្តំ សត្តា ឱបបាតិកា ឧត្តំ លោកេ សមណព្រាហ្មណា សម្មគ្គតា[๒] សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ចាតុម្មហាភូតិកោ អយំ បុរិសោ យទា កាលំ ករោតិ បថវី បថវីកាយំ អនុបេតិ អនុបគច្ឆតិ អាបោ អាបោកាយំ អនុបេតិ អនុបគច្ឆតិ តេជោ តេជោកាយំ អនុបេតិ អនុបគច្ឆតិ វាយោ វាយោកាយំ អនុបេតិ អនុបគច្ឆតិ អាកាសំ ឥន្ទ្រិ-យានិ សំកមន្តិ អាសន្ទិបញ្ចមា បុរិសា តំ[๓] អាទា-យ គច្ឆន្តិ យាវ អាឡាហនា បទានិ បញ្ញាយន្តិ[๔] កាបោតកានិ អដ្ឋីនិ ភវន្តិ ភស្សន្តា ហុតិយោ

---

๑ ម. បរោ លោកោ ។ ๒ ម. សមគ្គា សម្មគ្គតាតិបិ ទី. ជាហ. ទីឃនិ. ។ ๓ ម. ម. មរំ ។ ๔ ម. អាឡាហនា បទានិ បញ្ញាយន្តិ ។

អាក្រក់ មិនមានឡើយ លោកនេះ(១)មិនមាន លោកខាងមុខ(២)មិនមាន ប្រតិបត្តិខុសឬត្រូវកង់មាតា មិនមានផល (បុណ្យឬបាប) ការប្រតិបត្តិខុសឬត្រូវកង់បិតា មិនមានផល (បុណ្យឬបាប) សត្វជាឧបបាតិកៈកំណើត មិនមាន សមណៈនឹងព្រាហ្មណ៍ទាំងឡាយ ដែលមានសេចក្តីព្រមព្រៀងគ្នា ប្រតិបត្តិដោយប្រពៃ ធ្វើឲ្យជាក់ច្បាស់ ព្រោះត្រាស់ដឹងដោយខ្លួនឯង ហើយសំដែងនូវលោកនេះនឹងលោកខាងមុខ ក៏មិនមានក្នុងលោកឡើយ បុរសនេះប្រកបដោយមហាភូតរូប ៤ លុះខន្ធលមរណកាលកន្លងវេលាណា បឋវីធាតុខាងក្នុង ក៏ទៅជាបឋវីធាតុខាងក្រៅ អាបោធាតុខាងក្នុង ក៏ទៅជាអាបោធាតុខាងក្រៅ តេជោធាតុខាងក្នុង ក៏ទៅជាតេជោធាតុខាងក្រៅ វាយោធាតុខាងក្នុង ក៏ទៅជាវាយោធាតុខាងក្រៅ ឥន្ទ្រិយ (ទាំង ៦) ក៏រសាត់អណ្តែតទៅកាន់អាកាស ពួកបុរស (ទាំង ៤ នាក់) មានវេត្រជាគំរប់ ៥ សែងយកបុរសដែលស្លាប់ទៅនោះ ស្មាមដើង គឺគុណនឹងទោសក៏ឃ្លាតដនៅកំណត់ត្រឹមឈាបនដ្ឋានប៉ុណ្ណោះ សល់នៅតែឆ្អឹង មានសម្បុរ (ប្រផេះ) ដូចស្លាបនៃសត្វព្រាប ឯគ្រឿងសក្ការបូជាមានផែះជាទីបំផុត ទានេះពួក

១-២ អដ្ឋកថា ថា លោកនេះមិនមានដល់សត្វដែលបរិភោគក្នុងលោកខាងមុខ លោកខាងមុខមិនមានដល់សត្វដែលបរិភោគក្នុងលោកនេះ សត្វទាំងឡាយកើតក្នុងទីណា លុះប្បុគ្គលហើយក៏សូន្យក្នុងទីនោះ មិនកើតទៀតឡើយ ។

ឧត្តមញាតមំ ឆានំ តេសំ តុច្ឆំ មុសា វិលោ:ថា យេ
កេចិ អត្តំកភំ វទន្តិ ពាលេ ច បណ្ឌិតេ ច កា-
យស្ស កេចា ខុច្ឆិជ្ជន្តិ វិនស្សន្តិ ឆ ហោន្តិ បរំ មរ-
ណាតំ ឥត្តំ ខោ មេ ភន្តេ អដ្ឋិតោ តេសកម្ហលោ
សន្ធិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ ខុច្ចេនំ ព្យា-
កាសិ(១) សេយ្យថាបិ ភន្តេ អម្ពំ វា បុដ្ឋោ លពុជំ
ព្យាករេយ្យ លពុជំ វា បុដ្ឋោ អម្ពំ ព្យាករេយ្យ ឯវ-
មេវ ខោ មេ ភន្តេ អដ្ឋិតោ តេសកម្ហលោ សន្ធិដ្ឋិកំ
សាមញ្ញផលំ បុដ្ឋោ សមានោ ខុច្ចេនំ ព្យាកាសិ
តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ ហិ នាម មាទិ-
សោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ អប-
សាទេតព្ពំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ

---

๑ ម. ខច្ចេវាទំ វិយាកាសិ ។

សាមញ្ញផលសូត្រ ភាគ១របស់ព្រះសុត្តន្តបិដក

មនុស្សពាលកំឡៅបានបញ្ចុះកុមតហើយ ជនពាលឯណា ពោលពាក្យថា អំពើមានទានជាដើម មានផល ពាក្យរបស់ជនពាលនោះ ជាពាក្យកុហកទទេ ជនពាលគ្មានប្រាជ្ញាគ្មានបញ្ញា លុះបែកធ្លាយរាងកាយទៅ រមែងដាច់សូន្យ ប្រាត់ទៅ មិនកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ឡើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះឈ្មោះអជិតកេសកម្ពល កាលបើខ្ញុំព្រះអង្គសួរកេផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយដោយទុច្ចេទភាព (ពោលថាសត្វស្លាប់ទៅសូន្យ គ្មានកើតទៀត) ទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ ក៏បែរជាប្រាប់នូវដើមខ្នុរសម្ល វិញ ឬគេសួរពីដើមខ្នុរសម្ល ក៏បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន ព្រះឈ្មោះអជិតកេសកម្ពល កាលដែលខ្ញុំព្រះអង្គសួរកេផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយដោយទុច្ចេទភាពទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិតយ៉ាងនេះថា បុគ្គលប្រហែលអញ មិនសមបើទៅពប់អានសមណៈឬព្រាហ្មណ៍ អ្នកនៅអាស្រ័យកន្លែងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំ

អដ្ឋកថាស្ស កោសកកម្ពលស្ស ភាសិតំ នេវ អត្តន្តបៈ ឧបក្កិលេសាយ អត្តន្តបៈ ឧបក្កិលេសាយ អន្តមតោ អន្តមនភំ អដ្ឋង្គរេត្វា តមេវ ភវំ អនុក្កមិត្វា អនុក្កមិត្វា ខុជ្ជាយាសញ្ច បក្ខាមី ។

(៨៧) ឯកមិទាហំ ភន្តេ សមយំ យេន បក្កុធោ កច្ចាយនោ តេនុបសង្កមិំ ឧបសង្កមិត្វា បក្កុធេន កច្ចាយនេន សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ បក្កុធំ កច្ចាយនំ ឯតទវោចំ យថា នុ ខោ ឥមានិ ភោ កច្ចាយន បុថុសិប្បាយតនានិ ។បេ។ សក្កា នុ ខោ ភោ កច្ចាយន ឥធេវ ទិដ្ឋេ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញបេតុន្តិ ឯវំវុត្តេ ភន្តេ បក្កុធោ កច្ចាយនោ មំ ឯតទវោច សន្តមេ មហារាជ

ព្រះអង្គមិនបានត្រេកអរ មិនបានយាត់ហាមនូវភាសិតរបស់គ្រូឈ្មោះអ-
ជិតកេសកម្ពលឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានយាត់ហាម
ក៏មានសេចក្តីតូចចិត្ត តែមិនបានបញ្ចេញវាចា សំដែងនូវសេចក្តីតូចចិត្ត
មិនបានកាន់តាម មិនបានយកចិត្តទុកជាក់ទឹងវាចានោះទេ ក៏ក្រោកចាក
អាសនៈ ចៀសចេញទៅ ។

(៤៧) បពិត្រព្រះអង្គដ៏ចំរើន កុងក្រុងពាវគ្រឹះនេះ សម័យមួយ ខ្ញុំព្រះ
អង្គចូលទៅរកគ្រូឈ្មោះបកុធកច្ចាយនៈ លុះចូលទៅដល់ហើយ ក៏ពោល
ពាក្យពាក់ព័ន្ធ សំណេះសំណាលជាមួយនឹងគ្រូឈ្មោះបកុធកច្ចាយនៈ លុះ
បញ្ចប់នូវពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកលួងចិត្តកើតសេចក្តី
ស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំ
ព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ក៏ផ្តើមពាក្យសួរដូច្នេះ ទៅនឹងគ្រូឈ្មោះ
បកុធកច្ចាយនៈថា បពិត្រលោកកច្ចាយនៈដ៏ចំរើន ដូចជាសិល្បៈសម្រាប់
បង្កើតផលមានប្រមាណច្រើនពាន់ជាន់នេះ ។បេ។ បពិត្រលោកកច្ចាយនៈដ៏ចំ-
រើន លោកអាចនឹងបញ្ជាក់នូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់
ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងសិល្បៈទោះបានដែរឬ បពិត្រព្រះអង្គ
ដ៏ចំរើន កាលបើខ្ញុំព្រះអង្គ សួរយ៉ាងនេះហើយ គ្រូឈ្មោះបកុធកច្ចាយនៈ
បានឆ្លើយពាក្យដូច្នេះ មកនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ កាយ គឺពួក

កាយោ អកតោ អកតវិធោ អនិម្មិតា អនិម្មានា វញ្ឈា កូដ-
ដ្ឋា ឯសិកដ្ឋាយិដ្ឋិតា[1] តេ ន ឥញ្ជន្តិ ន វិបរិណាមន្តិ
ន អញ្ញមញ្ញំ ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ
វា ទុក្ខាយ វា សុខទុក្ខាយ វា កតមេ សត្ត បឋវីកាយោ
អាបោកាយោ តេជោកាយោ វាយោកាយោ សុខំ
ទុក្ខេ ជីវេ សត្តមេ[2] ឥមេ សត្តកាយា អកតា អ-
កតវិធោ អនិម្មិតា អនិម្មានា វញ្ឈា កូដដ្ឋា ឯសិ-
កដ្ឋាយិដ្ឋិតា តេ ន ឥញ្ជន្តិ ន វិបរិណាមន្តិ ន អញ្ញមញ្ញំ
ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ
វា សុខទុក្ខាយ វា តត្ថ ឆត្តិ ហន្តា វា ឃាតេតា វា
សោតា វា សាវេតា វា វិញ្ញាតា វា វិញ្ញាបេតា វា ឯសោ
ហិ[3] តិណ្ហេន សត្ថេន សីសំ ឯកេន កោចិ កញ្ចិ
ជីវិតា វោរោបេតិ សត្តន្នំយេវ កាយានំ អន្តរេន សត្ថ-
មនុបតតីតិ[4] ឥត្ថំ ខោ មេ កច្ចេ បកុធោ កច្ចាយនោ

---

១ ឯសិកដ្ឋាយិដ្ឋិកាតីបិ ជាហោ ។ ២ ខ. ជីវសត្តមេ ។ ៣ ខ, ម. សោ បិ ។
៤ ម. សត្តន្នំ ភ្លៅ កាយានមន្តរេន សត្ថំ វិវរមនុបគតីតិ ។ ខ. សត្តវិវរំ អនុបគតីតិ ។

ធាតុ ៧ នេះ គ្មាននរណាធ្វើកើត គ្មានវិធីធ្វើកើត គ្មាននរណានិម្មិតដោយឫទ្ធិបាន គ្មាននរណាសាងកើត ជាសភាវៈអ (គ្មានពូជតទៅទៀត) តាំងនៅដូចជាកំពូលភ្នំ បិតនៅមាំដូចជាសសរគោល តាយធាតុនោះមិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនទូវគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខ ឬឲ្យបានទុក្ខ ឬធាតុសុខធាតុទុក្ខទេ ឯកាយ គឺពួកធាតុ ៧ ដូចម្តេចខ្លះ គឺពួកធាតុដី ១ ពួកធាតុទឹក ១ ពួកធាតុភ្លើង ១ ពួកធាតុខ្យល់ ១ សេចក្តីសុខ ១ សេចក្តីទុក្ខ ១ ជីវិត ១ ជាគំរប់ ៧ តាយ គឺពួកធាតុ ៧ នេះ គ្មាននរណាធ្វើកើត គ្មានវិធីធ្វើកើត គ្មាននរណានិម្មិតដោយឫទ្ធិបាន គ្មាននរណាសាងកើត ជាសភាវៈអ តាំងនៅដូចជាកំពូលភ្នំ បិតនៅមាំដូចជាសសរគោល តាយធាតុនោះមិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនទូវគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខ ឬឲ្យបានទុក្ខ ឬធាតុសុខធាតុទុក្ខទេ បុគ្គលសម្លាប់ដោយខ្លួនឯងក្តី ប្រើគេឲ្យសម្លាប់ក្តី ស្តាប់ខ្លួនឯងក្តី ញុាំងគេឲ្យស្តាប់ក្តី ដំងច្បាស់ខ្លួនឯងក្តី ញុាំងអ្នកដទៃឲ្យដំងច្បាស់ក្តី មិនមានកូនតាយធាតុនោះឡើយ ទុកជាបុគ្គលនោះកាត់សីស:ដោយសស្ត្រាដ៏មុត ក៏ឈ្មោះថាគ្មានអ្នកណាផ្តាច់ផ្តិលអ្នកណាចាកជីវិតបាន ឯសស្ត្រាគ្រាន់តែចូលទៅតាមចន្លោះនៃកាយធាតុ ៧ ប៉ុណ្ណោះឯង បពិត្រព្រះអង្គដ៏ចំរើន ត្រួសៀកបក្កុធតថាយន:

សន្ធិដ្ឋកំ សាមញ្ញផលំ បុដ្ឋោ សមានោ អញ្ញេន អញ្ញំ ព្យាកាសិ សេយ្យថាបិ ភន្តេ អម្ហំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ វា បុដ្ឋោ អម្ហំ ព្យាករេយ្យ ឯវមេវ ខោ មេ ភន្តេ បកុធោ កច្ចាយនោ សន្ធិដ្ឋកំ សាមញ្ញផលំ បុដ្ឋោ សមានោ អញ្ញេន អញ្ញំ ព្យាកាសិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ ហិ នាម មាទិ. សោ សមណំ វា ព្រាហ្មណំ វា ទិដ្ឋតោ វិសន្ធិំ អបសាទេតព្ពំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ បកុធស្ស កច្ចាយនស្ស កាសិតំ នេវ អភិនន្ទិំ ន បដិក្កោសិំ អនភិនន្ទិត្វា អបដិក្កោសិត្វា អនត្តមនោ អនត្តមនភាវំ អនាបជ្ជិត្វា តមេវ ភវំ អនុក្កណ្ឋោ អនិក្កុជ្ឈន្តោ ឧដ្ឋាយាសនា បក្កាមិំ ។

(៩៨) ឯកមិទាហំ ភន្តេ សមយំ យេន ឯកសាលា ជដបុត្តោ តេនុបសង្កមិំ ឧបសង្កមិត្វា ឯកសាលេន

កាលបើខ្ញុំព្រះអង្គសួរភេទផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយដោយរឿងដទៃផ្សេងទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ បែរជាប្រាប់នូវដើមខ្នុរសម្ងាវិញ ឬគេសួរពីដើមខ្នុរសម្ង បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន ត្រង់ឈ្មោះបកុធកច្ចាយនៈ កាលដែលខ្ញុំព្រះអង្គសួរភេទផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងហើយ ក៏បែរជាដោះស្រាយដោយរឿងដទៃផ្សេងទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិតយ៉ាងនេះថា បុគ្គលប្រហែលអញ មិនសមបើទៅជាប់អាននឹងសមណៈឬព្រាហ្មណ៍អ្នកនៅអាស្រ័យក្នុងវែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាមនូវភាសិតរបស់ត្រង់ឈ្មោះបកុធកច្ចាយនៈឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម ក៏មានសេចក្តីតូចចិត្តដែរ តែមិនបានបញ្ចេញភាសំដែងនូវសេចក្តីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងភាសានោះទេ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។

(៤៨) បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងភគ្គនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកត្រង់ឈ្មោះនិគណ្ឋនាដបុត្ត លុះចូលទៅដល់ហើយ ក៏ពោល

ជាតបុត្តេន សទ្ធឹ សម្ពោធឹ សម្ពោធនីយំ កថំ សាក-
ណាយំ វីតសោកត្តា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ
ខោ អហំ ភន្តេ ឩតណ្ហំ ជាតបុត្តំ ឯតទវោចំ យថា
ន្តុ ខោ ឥមានិ កោ អត្ថវេស្សន បុថុសិប្បាយតនានិ
។បេ។ សក្កា នុ ខោ កោ អត្ថវេស្សន ឯវមេវ និដ្ឋ
វ ឆម្មេ សន្និដ្ឋកំ សាមញ្ញផលំ បញ្ញបេតុន្តិ ឯវំ វុត្តេ
ភន្តេ ឩតណ្ហោ ជាតបុត្តោ មំ ឯតទវោច ឥធ មហា-
ភជ ឩតណ្ហោ ជាតុយាមសំវរសំវុតោ ហោតិ កាជញ្ញ
ខោ(១) មហាភជ ឩតណ្ហោ ជាតុយាមសំវរសំវុតោ
ហោតិ ឥធ មហាភជ ឩតណ្ហោ សព្ពវារិវារិតោ ច
ហោតិ សព្ពវារិយុត្តោ ច សព្ពវារិធុតោ ច សព្ពវារិផុ-
ដោ ច ឯវំ ខោ មហាភជ ឩតណ្ហោ ជាតុយាមសំ-

---

១ ឧ ម. ហោតិ ឧ ទិស្សតិ ។

សាចញ្ញផលសូត្រ ទី១ នៃវគ្គទី៣ ឈ្មោះនិគណ្ឋៈ

ពាក្យកាត់ទាក់សំណេះសំណាល ជាមួយនឹងគ្រូឈ្មោះនិគណ្ឋនាដបុត្ត លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួរលឹក ល្មមឲ្យកើតសេចក្តីសិទ្ធស្កាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ឃានផ្តើមពាក្យសួរដូច្នេះនឹងគ្រូឈ្មោះនិគណ្ឋនាដបុត្តថា បពិត្រលោកអគ្គិវេស្សនៈដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ។បេ។ បពិត្រលោកអគ្គិវេស្សនៈដ៏ចំរើន លោកម្ចាស់ពួកនឹងបញ្ញត្តនូវផលនៃសមណភាពដែរឬ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនេះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះនិគណ្ឋនាដបុត្តឆ្លើយពាក្យដូច្នេះ មកនឹងខ្ញុំព្រះអង្គថា បពិត្រមហាពាជ កាលណាលោកនេះនិគ្រន្ថបានសង្រួមដោយការសង្រួម មាន ៤ ចំណែក បពិត្រមហាពាជ និគ្រន្ថដែលបានសង្រួមដោយការសង្រួម មាន ៤ ចំណែក (នោះ) តើដូចម្តេចខ្លះ បពិត្រមហាពាជ និគ្រន្ថក្នុងលោកនេះ ឃាត់ហាមទឹកគាំងពួន(១) ១ ប្រកបដោយទឹកគាំងពួន(២) ១ កំចាត់ជាបដោយទឹកគាំងពួន(៣) ១ ព្រោះព្រំដោយទឹកគាំងពួន(៤) ១ បពិត្រមហាពាជ និគ្រន្ថ

---

១ អដ្ឋកថាថា ឃានហាមឃាត់ទឹកត្រជាក់គ្រប់មុខដោយសំគាល់ថា ក្នុងទឹកត្រជាក់មានសត្វ មិនត្រូវប្រើប្រាស់ឡើយ ។ ២ ប្រកបដោយការរាំងផ្លូវបាបទាំងពួង ។ ឯកាថា ប្រកបដោយការសង្រួមគ្រប់ប្រការ ។ ៣ កំចាត់បាប ដោយការរាំងផ្លូវបាបទាំងពួង ។ ៤ ព្រោះព្រំដោយការរាំងផ្លូវបាបទាំងពួង (តាមន័យនៃអដ្ឋកថាខាងដើមកា ត្រង់ពាក្យថាទឹក ។ ក្នុងទី ២-៣-៤-នោះ ជាឈ្មោះនៃការរាំងផ្លូវបាប ។

វាសំវុតោ ហោតិ យតោ ខោ មហារាជ ឯកច្ចោ
ឃរំ ឯតុយាមសំវាសំវុតោ ហោតិ អយំ វុច្ចតិ មហារាជ
ឯកច្ចោ កតត្តោ ច យតត្តោ ច ឋិតត្តោ ចាតិ ឥទំ ខោ
មេ កត្តេ ឯកច្ចោ ឆាដបុត្តោ សន្ធិដ្ឋកំ សាមញ្ញ
បុដ្ឋោ សមានោ ចាតុយាមសំវរំ ព្យាកាសិ សេយ្យ-
ថាបិ កត្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាការេយ្យ
លពុជំ វា បុដ្ឋោ អម្ពំ ព្យាការេយ្យ ឯវមេវ ខោ
មេ កត្តេ ឯកច្ចោ ឆាដបុត្តោ សន្ធិដ្ឋកំ សាមញ្ញ-
ផលំ បុដ្ឋោ សមានោ ចាតុយាមសំវរំ ព្យាកាសិ
តស្ស មយ្ហំ កត្តេ ឯតទហោសិ កថំ ហិ នាម
អាឥសោ សមណំ វា ព្រាហ្មណំ វា វិដ្ឋតេ វិសន្តិ
អបសាឋេតព្ពំ មញ្ញេយ្យាតិ សោ ខោ អហំ កត្តេ
ឯតស្សាស្ស ឆាដបុត្តស្ស ភាសិតំ ឧជុ អកិឆ្ឍ្រេ ឆប្ប-

ជានសង្រ្គម ដោយការសង្រ្គម មាន ៤ ចំណែកយ៉ាងនេះឯង បពិត្រ
មហារាជ កាលណា និគ្រន្ថជានសង្រ្គម ដោយការសង្រ្គម ៤ ចំ-
ណែកយ៉ាងនេះ បពិត្រមហារាជ និគ្រន្ថនេះ គេហៅថា អ្នកមាន
ខ្លួនដល់នូវទីបំផុតផង មានខ្លួនសង្រ្គមហើយផង មានខ្លួននៅដោយល្អ
ផង បពិត្រព្រះអង្គដ៏ចំរើន ឯគ្រូឈ្មោះនិគណ្ឋនាដបុត្ត កាលដែលខ្ញុំ
ព្រះអង្គសួរភេផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ ដោយខ្លួនឯង
ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយទៅរកការសង្រ្គមមាន ៤
ចំណែកទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពី
ដើមស្វាយ បែរជាក្រាប់នូវដើមខ្នុរសម្ងូវិញ ឬគេសួរពីដើមខ្នុរសម្ង
បែរជាក្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះនិ-
គណ្ឋនាដបុត្ត កាលដែលខ្ញុំព្រះអង្គសួរភេផលនៃសមណប្បដិបត្តិ ដែល
ឃើញច្បាស់ដោយខ្លួនឯង ក៏បែរជាដោះស្រាយទៅរកការសង្រ្គមមាន ៤
ចំណែកទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តី
រំពឹតដូច្នេះថា បុគ្គលប្រហែលអញ មិនសមបើទៀបនឹងសមណៈ
ឬព្រាហ្មណ៍ អ្នកនៅអាស្រ័យកន្លែងដែន ដែលជាបុគ្គលគួរបៀតបៀន
សោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានយាត់
ហាមនូវកាសិតរបស់គ្រូឈ្មោះនិគណ្ឋនាដបុត្តឡើយ លុះខ្ញុំព្រះអង្គមិនបាន

ฉกฺกาสึ อนภิญฺญาตา อปฺปฉกฺกาสิกา อนตฺตมนา อนตฺตมนตาย อนิจฺฉาเรา ตเมว ภยํ อนุกฺกณฺฐาย อนิกฺกุชฺเฌน ทุฏฺฐายาสนา ปกฺกามึ ฯ

(๙๙) ฯกทา มหาราช ภควา สมยํ ยเน สญฺญายาเวลฏฺฐปุตฺตา เตนุปสงฺกมึ อุปสงฺกมิตฺวา สญฺญายเนน เวลฏฺฐปุตฺเตน สทฺธึ สมฺโมทึ สมฺโมทนียํ กถึ สาราณียึ วีติสาเรตฺวา ฯกมนฺตํ นิสีทึ ฯกมนฺตํ นิสินฺโน โข อหํ ภควา สญฺญยึ เวลฏฺฐปุตฺตึ ฯตทวเจ ยถา นุ โข ภนฺเต สมณา โก สญฺญย ปุถุสิปฺปายตนานิ ฯเป ฯ สกฺกา นุ โข โก สญฺญย ฯาเมว นิเสฺว ฯ ธมฺเม สนฺทิฏฺฐิกึ สามญฺญผลึ ปญฺหเปตุนฺติ ฯึ ปุจฺฉิ ภควา สญฺญายเนน เวลฏฺฐปุตฺเตน มหาราช ฯตทวเจ อตฺถิ ปเร โลเกติ สติ เจ มึ ปุจฺฉสิ อตฺถิ ปเร โลเกติ สติ เจ เม อสฺส อตฺถิ ปเร โลเกติ สติ เต

ត្រេកអរ មិនបានយាត់ហាម ក៏មានសេចក្តីតូចចិត្តដែរ តែមិនបានបញ្ចេញវាចា សំដែងនូវសេចក្តីតូចចិត្ត មិនបានតាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយត្រាកចាកអាសនៈ ចៀសចេញទៅ ។

(៤៨) បពិត្រព្រះអង្គដ៏ចំរើន កាលក្រោយពីដូច្នេះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកគ្រូឈ្មោះសញ្ជ័យវេលដប្បត្តិ លុះចូលទៅដល់ហើយ ក៏ពោលពាក្យពាក់ព័ន្ធសំណេះសំណាល នឹងគ្រូឈ្មោះសញ្ជ័យវេលដប្បត្តិ លុះបញ្ចប់នូវពាក្យដែលគួររីករាយ នឹងពាក្យដែលគួរលឹក ល្មមឲ្យកើតសេចក្តីសិនស្មាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានផ្តើមពាក្យសួរដូច្នេះទៅនឹងគ្រូឈ្មោះសញ្ជ័យវេលដប្បត្តិថា បពិត្រលោកសញ្ជ័យដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណប្រើនទាំងនេះ។បេ។ បពិត្រលោកសញ្ជ័យដ៏ចំរើន លោកអាចនឹងបញ្ជាក់ផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះសញ្ជ័យវេលដប្បត្តិ ឆ្លើយពាក្យដូច្នេះមកនឹងខ្ញុំព្រះអង្គថា បើមហាពាជសួរអាត្មាថា លោកខាងមុខមានដែរឬ បើសេចក្តីយល់ឃើញរបស់អាត្មាថា លោកខាងមុខមាន អាត្មាគប្បីដោះស្រាយនូវហេតុនោះដល់ព្រះអង្គថាលោកខាងមុខមាន

ឯ(១) ព្យាករេយ្យ ឯវន្តិបិ(២) មេ នោ តថាតិបិ មេ នោ
អញ្ញថាតិបិ មេ នោ នោតិបិ មេ នោ នោ នោតិបិ មេ
នោ នត្ថិ បរេ លោកោ អត្ថិ ច នត្ថិ ច បរេ លោកោ
នេវ អត្ថិ ន នត្ថិ បរេ លោកោ អត្ថិ សត្តា ឱបបាតិកា
តិកា នត្ថិ សត្តា ឱបបាតិកា អត្ថិ ច នត្ថិ ច សត្តា
ឱបបាតិកា នេវ អត្ថិ ន នត្ថិ សត្តា ឱបបាតិកា អត្ថិ
សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ នេ
មំ បុច្ឆសិ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ
អត្ថិ នេ មេ អស្ស អត្ថិ សុកតទុក្កដានំ កម្មានំ
ផលំ វិបាកោ អត្ថិ តេ ឯំ ព្យាករេយ្យំ នត្ថិ សុ-
កតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ ច
នត្ថិ ច សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ

---

១ តេនាតិបិ ទិស្សតិ ។ ២ ខ. ឯវម្បិ ។

ឯសេចក្តីយល់ឃើញរបស់អាត្មាថា យ៉ាងនេះក៏មិនមែន(១) សេចក្តីយល់ឃើញរបស់អាត្មាថាយ៉ាងនោះក៏មិនមែន(២) សេចក្តីយល់ឃើញរបស់អាត្មាថាយ៉ាងដទៃក៏មិនមែន(៣) សេចក្តីយល់ឃើញរបស់អាត្មាថាមិនមែនក៏ទេ(៤) សេចក្តីយល់ឃើញរបស់អាត្មាថា មិនមែនទេ ក៏មិនមែនដែរ(៥) (សេចក្តីយល់ឃើញរបស់អាត្មាថា) លោកខាងមុខមិនមាន លោកខាងមុខមានខ្លះ មិនមានខ្លះ លោកខាងមុខមានក៏មិនមែន មិនមានក៏មិនមែន ពួកសត្វជាឧបបាតិក:មាន ពួកសត្វជាឧបបាតិក:មិនមាន ពួកសត្វជាឧបបាតិក:មានខ្លះមិនមានខ្លះ ពួកសត្វជាឧបបាតិក:មានក៏មិនមែន មិនមានក៏មិនមែន បើមហាពាជសូរអាត្មាថា ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់មានដែរឬ បើសេចក្តីយល់ឃើញរបស់អាត្មាថា ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់មាន អាត្មាគប្បីដោះស្រាយនូវហេតុនោះ ដល់ព្រះអង្គថា ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់មាន ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់ មិនមាន ផលវិបាកនៃកម្ម

---

១ អដ្ឋកថា ថា ពាក្យថាយ៉ាងនេះក៏មិនមែន ជាពាក្យឃាត់អាការសួរណា ៗ ដែលមិនមានទីកំណត់ ។ ២ ពាក្យថាយ៉ាងនោះក៏មិនមែន ជាពាក្យឃាត់សស្សតវាទ គឺពាក្យថា លោកទៀង ។ ៣ ពាក្យថាយ៉ាងដទៃក៏មិនមែន ជាពាក្យឃាត់ឯកច្ចសស្សតវាទ ឯកច្ចអសស្សតវាទ គឺពាក្យថាលោកទៀងខ្លះមិនទៀងខ្លះ ។ ៤ ពាក្យថាមិនមែនក៏ទេ ជាពាក្យឃាត់ទេញ្ញេវាទ គឺពាក្យថាសត្វស្លាប់ទៅស្មុគស្មាញមិនតើតទៀត ។ ៥ ពាក្យថាមិនមានក៏ទៅក៏មិនមែនដែរ ជាពាក្យឃាត់តក្កីវាទ គឺពាក្យថា សត្វស្លាប់ទៅមិនមែនជាមានមិនមែនជាគ្មាន ។

នេវ អត្តំ ន នត្តំ សុភគជុក្កជាតំ តម្ហាតំ ផលំ វិចាគោ ហោតំ តថាគតោ បរម្មរណា ន ហោតំ តថាគតោ បរម្មរណា ហោតំ ច ន ច ហោតំ[1] តថាគតោ បរម្មរណា នេវ ហោតំ ន ន ហោតំ តថាគតោ បរម្មរណាតំ ឥតំ ចេ មំ បុច្ឆសិ នេវ ហោតំ ន ន ហោតំ តថាគតោ បរម្មរណាតំ ឥតំ ចេ មេ អស្ស នេវ ហោតំ ន ន ហោតំ តថាគតោ បរម្មរណាតំ ឥតំ តេ តំ ព្យាករេយ្យំ ឯវន្តំបិ មេ នោ តថាតំបិ មេ នោ អញ្ញថាតំបិ មេ នោ នោតំបិ មេ នោ នោ នោតំបិ មេ នោតំ ឥតំ្ត ខោ មេ ភន្តេ សញ្ញយោ វេលដ្ឋបុត្តោ សន្ថិដ្ឋតំ សាមញ្ញផលំ បុដ្ឋោ សមានោ វិក្ខេបំ ព្យាកាសិ សេយ្យថាបិ ភន្តេ អត្ថិ ភ បុដ្ឋោ លតុដំ ព្យាករេយ្យ លតុដំ ភ បុដ្ឋោ

---

๑ ឧ. ម. ន ហោតំ ច ។

ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់មានខ្លះមិនមានខ្លះ ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់ មានក៏មិនមែន មិនមានក៏មិនមែន បើមហាពាសសួរអាត្មាថា ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ សត្វមិនកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះ ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះឬ បើសេចក្តីយល់ឃើញរបស់អាត្មាថា ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន អាត្មាគប្បីដោះស្រាយនូវហេតុនោះ ដល់ព្រះអង្គថា ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថាយ៉ាងនេះ ក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថា យ៉ាងនោះក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថាយ៉ាងដទៃក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថា មិនមែនក៏ទេ សេចក្តីយល់ឃើញរបស់អាត្មាថា មិនមែនទេ ក៏មិនមែនដែរ បពិត្រព្រះអគ្គដ៏ចំរើន ត្រូឈ្មោះសញ្ជ័យលើសជាងបុគ្គលដែលគេសួរនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយបន្ទុបន្ទប់ទៅវិញ បពិត្រព្រះអគ្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ បែរជាច្រាប់នូវដើមខ្នុរសម្ងូវិញ ឬគេសួរពីដើមខ្នុរសម្ងូ

អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ កន្តេ សញ្ជយោ
វេលដ្ឋបុត្តោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ
វិក្ខេបំ ព្យាការំ តស្ស មយ្ហំ កន្តេ ឯតទហោសិ
អយញ្ច ភវមេសំ សមណព្រាហ្មណានំ សព្ពញ្ញោ
សព្ពទស្សាវី កថំ ហិ នាម សន្ទិដ្ឋិកំ សាមញ្ញផលំ
បុដ្ឋោ សមានោ វិក្ខេបំ ព្យាករិស្សតីតិ តស្ស មយ្ហំ
កន្តេ ឯតទហោសិ កថញ្ចិ នាម មាទិសោ សមណំ
វា ព្រាហ្មណំ វា វិជិតេ វសន្តំ អបសាទេតព្ពំ មញ្ញ-
ិស្សតីតិ សោ ខោ អហំ កន្តេ សញ្ជយស្ស វេលដ្ឋបុត្តស្ស
ភាសិតំ នេវ អភិនន្ទិំ ន បដិក្កោសិំ អនភិនន្ទិត្វា
អបដិក្កោសិត្វា អនត្តមនោ អនត្តមនភាវំ អវិញ្ញាបេត្វា
តមេវ ភវំ អនុក្កណ្ឋោ អនិក្កុជ្ឈន្តោ ឧដ្ឋាយាសនា
បក្កាមិំ ។

បៃវេជាក្រុមប់ទូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះសញ្ជយ-
វេលដ្ឋបុត្ត កាលដែលខ្ញុំព្រះអង្គសួរកេផល នៃសមណបព្វជិបត្តិ ដែល
ឃើញច្បាស់ដោយខ្លួនឯង ក៏បៃវេជាដោះស្រាយបន្ទូបន្ទប់ទៅវិញ ដូច្នោះ
ឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះថា គ្រូឈ្មោះ
សញ្ជយវេលដ្ឋបុត្តនេះឯង លុងដ្រុល វង្វេងដ្រុល ជាងសមណៈទំង
ព្រាហ្មណ៍តាំងច្បាយពួកនេះ កាលបើអញសួរត្រង់ផល នៃសមណបព្វ-
ជិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងហើយ មិនសមបើទៅដោះស្រាយ
បន្ទូបន្ទប់សោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះ
ថា បុគ្គលប្រហែលអញ មិនសមបើទៅពាប់អានសមណៈឬព្រាហ្មណ៍
អ្នកទៅអាស្រ័យក្នុងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះ
អង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានយាត់ហាមនូវភាសិតរបស់
គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបាន
យាត់ហាម ក៏មានសេចក្តីតូចចិត្តដែរ តែមិនបានបង្ហោះញាកចាសំដែង
នូវសេចក្តីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចា
នោះទេ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។

(១០០) សោហំ ភន្តេ ភគវន្តម្បិ បុច្ឆាមិ យថា ន្ទុ
ខោ ឥមានិ ភន្តេ បុថុសិប្បាយតនានិ សេយ្យថីទំ ហត្ថា-
រោហា អស្សារោហា រថិកា ធនុគ្គហា ចេលកា ចលា-
កា បិណ្ឌាចារិកា ខត្តា ភដបុត្តា បក្ខន្ទិនោ មហា-
នាគា សូរា ចម្មយោធិនោ ទាសកបុត្តា អាឡារិកា
កប្បកា ន្ហាបកា សូទា មាលាការ រជកា បេ-
សការ ន្ហលការ កុម្ភការ គណាការ មុទ្ទិកា យានិ
វា បនញ្ញានិបិ តថារូបានិ បុថុសិប្បាយតនានិ តេ ទិដ្ឋេ
ធម្មេ សន្ទិដ្ឋិកំ សិប្បផលំ ខុបជីវន្តិ តេ តេន អត្តានំ
សុខេន្តិ បិណេន្តិ មាតាបិតរោ សុខេន្តិ បិណេន្តិ បុត្តទារំ

(១០០) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមសួរចំពោះព្រះមានព្រះភាគ សូមទ្រង់ព្រះមេត្តាប្រោស ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ចានដល់សិល្បៈរបស់បុគ្គលនោះៗ គឺសិល្បៈរបស់បុគ្គលអ្នកកាន់ការខាងដំរី អ្នកកាន់ការខាងសេះ អ្នកកាន់ការខាងរថ ពួកខ្មាន់ធ្នូ ពួកអ្នកកាន់ទង់ជ័យ (មុខ) ពួកអ្នកចាត់ចែង ពួកអ្នកបញ្ជូនសេ្បៀង ពួកព្រះរាជបុត្តអ្នកពុះពារ (លុកចូលកងសង្គ្រាម) ពួកអ្នកសុំចូលទៅកងសង្គ្រាម (អ្នកយកអាសា) ពួកយោធាអ្នកអង់អាច ពួកសេនាអ្នកក្លៀវក្លា ពួកយោធាអ្នកពាក់អាវក្រោះ ពួកកូននៃជនជាទាសៈ (ដែលជាទីស្រេឡាញ់នៃចៅហ្វាយនាយ) ពួកអ្នកធ្វើនំ ពួកជាងកោរកាត់ ពួកអ្នកផតទឹក ពួកអ្នកធ្វើអាហារ ពួកជាងក្រងផ្កា ពួកជាងជ្រលក់ ពួកជាងតម្បាញ ពួកជាងត្បាញផែង ពួកសន្ទឹងធ្មឹង ពួកអ្នកចេះលេខនព្វន្ត ពួកអ្នកចេះពាប់ដោយម្រាមដៃទេ ពុំនោះសោត សិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនឯណានីមួយដទៃទៀត ដែលមានបែបយ៉ាងនេះក្តី បុគ្គលទាំងនោះរមែងចិញ្ចឹមជីវិតអាស្រ័យនូវផលរបស់សិល្បៈ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន បុគ្គលទាំងនោះ រមែងធ្វើនូវខ្លួនឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ (ដោយកម្លាំងកាយកម្លាំងប្រាជ្ញា) រមែងធ្វើមាតាបិតាឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើនូវកូននឹងប្រពន្ធឲ្យដល់

សុខេត្តំ បដិលភិត្តំ មគ្គាមគ្គេ សុខេត្តំ បដិលភិត្តំ សមណ-
ព្រាហ្មណេសុ ខុទ្ទកំ ធនំ លភិត្តំ បតិដ្ឋាបេត្តំ សោវត្តិកំ
សុខវិបាកំ សគ្គសំវត្តនិកំ សក្កា នុ ខោ តេន ឥមេ ធម-
ម្មេ ធនត្ថេ វតម្មេ សន្ធិដ្ឋកំ សាមញ្ញលំ បញ្ញាបេតុន្តិ។
សក្កា(១) មហារាជ តេនហិ មហារាជ តាញ្ញេវត្ថ បដិ-
បុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា តំ(២) ព្យាករេយ្យាសិ
តំ កិំ មញ្ញសិ មហារាជ អត្ថិ តេ អស្ស បុរិសោ នានា
កម្មករោ បុព្ពុដ្ឋាយី បច្ចានុចារី កិំការប្បដិស្សាវី
មនាបចារី បិយភាណី មុខុល្លោកាលោ តស្ស ឥមស្ស

---

១ ឱ. សក្ក នុ ខោ ។ ២ ឱ. តំ ។

នូវសេចក្តីសុខឲ្យពេញលេញ រមែងធ្វើមិត្តអាមាត្យឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងញុំាងទក្ខិណាទាន ដែលមានផលដ៏ខ្ពស់ ជាទានគួរដល់កិរិយាកើតក្នុងឋានសួគ៌ ជាទានមានផលនាំមកនូវសេចក្តីសុខ ជាទានញុំាងធម៌ទាំង ១០ ដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយល្អ ឲ្យតម្កល់នៅក្នុងសមណៈនិងព្រាហ្មណ៍ទាំងឡាយ ដោយសិល្បៈនោះ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចនឹងបញ្ជាក់ នូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហាកដ តថាគតអាច (បញ្ជាក់បាន) បពិត្រមហាកដ បើដូច្នោះ តថាគតសូមសួរមហាកដ ក្នុងហេតុនោះវិញ មហាកដគាប់ព្រះពាក្យហឫទ័យយ៉ាងណា គប្បីដោះស្រាយនូវប្រស្នានោះយ៉ាងនោះចុះ ។ បពិត្រមហាកដ ចុះព្រះអង្គសំគាល់នូវហេតុនោះដូចម្តេច កន្លៅលោកនេះ (បើ) មហាកដមានបុរសជាខ្ញុំបម្រើ អ្នកធ្វើការជាអ្នកក្រោកឡើងមុន[1]នឹងដេកក្រោយ ជាអ្នកទទួលស្តាប់កន្លងកិច្ចការឯណានីមួយ ជាអ្នកប្រព្រឹត្តធ្វើនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យជាទីស្រឡាញ់ ជាអ្នកបង្ហាញមុខ (ម្ចាស់) បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះ

---

១ អដ្ឋកថា ថា បុរសជាខ្ញុំបម្រើ៣នេះ ឃើញម្ចាស់ មកអំពីចម្ការមែងក្រោកឡើងមុន ដើម្បីទទួលដំណើរហើយក្រោលអាសនៈទាំងធ្វើនូវកិច្ច ដែលគួរធ្វើមានទឹកសម្រាប់លាងជើងជាដើម រួចទើបដេកក្រោយ ។

សាមញ្ញផលសូត្រ ការទ្រង់សំដែងដំណើរនៃសមណព្រាហ្មណ៍ដទៃ ដែលឃើញច្បាស់ដោយខ្លួនឯង ថា អើហ្ន៎ ហេតុអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុចម្លែកពេកណាស់ នេះជាគតិរបស់បុណ្យ នេះជាវិបាករបស់បុណ្យ ព្រោះថាព្រះបាទអជាតសត្តុវេទេហីបុត្តជាធំក្នុងដែនមគធៈនេះ ក៏ជាមនុស្ស ឯអាត្មាអញក៏ជាមនុស្សដែរ ប៉ុន្តែព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងដែនមគធៈនេះ ទ្រង់ផ្គត់ផ្គង់ស្កប់ស្កល់ដោយកាមគុណ ៥ មានគេបម្រើហាក់ដូចជាទេវតា ឯអាត្មាអញជាខ្ញុំបម្រើ អ្នកធ្វើការងារ ជាអ្នកក្រោកឡើងមុន ដេកក្រោយ ជាអ្នកទទួលស្តាប់ កន្ត ការនីមួយ ជាអ្នកប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យជាទីស្រឡាញ់ ជាអ្នកបង្ហាញមុខ (ម្ចាស់) អាត្មាអញគួរធ្វើបុណ្យ ដូចជាបុណ្យព្រះពាជានោះ បើដូច្នេះ មានតែអាត្មាអញកោរសក់ នឹងពុកមាត់ពុកចង្កាចេញ ហើយស្លៀកដណ្តប់សំពត់កាសាយៈ ចាំងឡាយ ចេញចាកផ្ទះហើយចូលទៅកាន់ផ្ទះ ។ សម័យខាងក្រោយមក បុរសនោះក៏កោរសក់នឹងពុកមាត់ពុកចង្កាចេញ ហើយស្លៀកដណ្តប់សំពត់កាសាយៈចាំងឡាយចេញចាកផ្ទះហើយចូលទៅកាន់ផ្ទះ ។ លុះបុរសនោះ ចានបួសយ៉ាងនេះហើយ ក៏សង្រួមកាយ សង្រួមវាចា សង្រួមចិត្តគ្រប់គ្រងវិយោបថ សន្តោសដោយគ្រឿងបរិភោគនឹងគ្រឿងស្លៀកដណ្តប់ដ៏ទុតម ត្រេកអរចំពោះទីស្ងាត់ ។ មានបុរស ១ ពួកទៀត ក្រាបទូល

អច្ចយំ វត តោ អត្ថតំ វត តោ បុញ្ញានំ កតំ បុញ្ញានំ
វិចារោ អយំ ហិ ភន្តេ មាគធោ អជាតសត្តុ
វេទេហីបុត្តោ មនុស្សោ អហំបិ មនុស្សោ អយំ ហិ
ភន្តេ មាគធោ អជាតសត្តុ វេទេហីបុត្តោ បញ្ចហិ តោ-
មកុណេហិ សមប្បតោ សមង្គីភូតោ បរិចារេតិ នេវ
មញ្ញេ អហំ បនម្ហិ សព្ពញ្ញូ(១) ទិដ្ឋោ តោ កម្មកិរេ បុព្ពុដ្ឋាយី
បច្ចានិចាតី កិំការប្បដិសព្ពាវី មធាបថារី បិយភាណី
មុខុល្លោកកិំ តោ(២) នេវ វតិស្សាហំ បុញ្ញានំ កិរេយ្យំ
យន្ទូនាហំ តេសមស្សំ ទិហារេត្វា តាសាយានំ វត្តានំ
អច្ឆាទេត្វា អតារស្មា អនតារិយំ បព្ពជេយ្យន្តិ ។
សោ អបរេន សមយេន តេសមស្សំ ទិហារេត្វា
តាសាយានំ វត្តានំ អច្ឆាទេត្វា អតារស្មា អនតារិយំ
បព្ពជេយ្យ ។ សោ ឯវំ បព្ពជិតោ សមានោ តាយេន
សំវុតោ វិហរេយ្យ ភថាយ សំវុតោ វិហរេយ្យ មនសា
សំវុតោ វិហរេយ្យ ឃាសច្ឆាទនបរមតាយ សន្តុដ្ឋោ
អភិរតោ បវិវេកេ ។ តតោ តេ(៣) បុរិសា ឯតមាចេយ្យុំ

---

១ អហំ បនម្ហិ សព្ពញ្ញូតិបិ ជាហេ ។ ២ ខ មុខុល្លោកកោ ។ ៣ ខ ម. តំ ចេ តេ ។

យត្ថេ នេវ ជានេយ្យាសិ យោ តេ សោ(១) បុរិសោ ឥមាសោ កម្មករោ បុព្ពុដ្ឋាយី បដ្ឋានិធាតី កិំការប្ប-ដិសព្ពរី មនាបចារី បិយវាទី មុខុល្លោកិនោ សោ នេវ កោសមសុំ ឱបញ្ញេត្វា ឥមាសាយានិ វត្តានិ អច្ឆាទេត្វា អតារស្មា អនតារយំ បព្ពជិតោ សោ ឥមំ បព្ពជិតោ សមានោ កាយេន សំវុតោ វិហរតិ ឥមាយ សំវុតោ វិហរតិ មនសា សំវុតោ វិហរតិ ឃាសច្ឆាទនមត្តាយ សន្តុដ្ឋោ អតិរេកោ បរិវេកតិ ។ អបិនុ ត្វំ ឥមំ នេយ្យាសិ ឯតុ មេ កោ សោ បុរិសោ បុនទេវ ហោតុ ឥមាសោ កម្មករោ បុព្ពុដ្ឋាយី បដ្ឋានិធាតី កិំការប្បដិសព្ពរី មនាបចារី បិយវាទី មុខុល្លោកិនោតិ ។ នោហេតំ ភន្តេ អថខោ ំ មយមេវ អតិភនេយ្យាមបិ បច្ចុដ្ឋេ-

---

១ វិ. ម. សោតិ បាឋោ ន ទិស្សតិ ។

មហាភដយ៉ាងនេះថា សូមព្រះភដតេជះតម្កល់លើក្បូង បពិត្រព្រះសម្មតិ-
ទេព សូមព្រះអង្គជ្រាប បុរសដែលជាខ្ញុំបម្រើ អ្នកធ្វើភដការរបស់ព្រះអង្គ
ជាអ្នកក្រោកឡើងមុន ដេកក្រោយ ជាអ្នកទទួលស្តាប់ពាក្យ ក្នុងកិច្ចការ
នីមួយ ជាអ្នកប្រព្រឹត្តធ្វើនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យជាទី
ស្រឡាញ់ ជាអ្នកបង្ហាញមុខ (ម្ចាស់) បពិត្រព្រះសម្មតិទេព បុរសនោះ
គោរសក់នឹងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ
ចេញចាកផ្ទះហើយចូលទៅកាន់ផ្សារ លុះបុរសនោះ ចាននួសយ៉ាងនេះ
ហើយក៏សង្រួមកាយ សង្រួមវាចា សង្រួមចិត្ត គ្រប់គ្រងវិយោបថ សន្តោស
ដោយគ្រឿងបរិភោគ នឹងគ្រឿងស្លៀកពាក់ដ៏ឧត្តម ត្រេកអរចំពោះទី
ស្ងាត់ ។ ចុះមហាភដគួរពោលយ៉ាងនេះថា អើ បុរសនោះត្រូវចូលមក (ទៅ
ក្នុងសំណាក់) អញវិញ ត្រូវមកធ្វើជាខ្ញុំបម្រើអញ អ្នកធ្វើភដការ ជាអ្នក
ក្រោកមុន ដេកក្រោយ ជាអ្នកទទួលស្តាប់ពាក្យ ក្នុងកិច្ចការនីមួយ ជា
អ្នកប្រព្រឹត្តធ្វើនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យ ជាទីស្រឡាញ់
ជាអ្នកបង្ហាញមុខ (ម្ចាស់) ដូច្នេះដែរឬ ។ ព្រះភជាក្រាបបង្គំទូលថា បពិត្រ
ព្រះអង្គដ៏ចំរើន ហេតុនោះមិនមែនដូច្នោះទេ តាមពិត យើងខ្ញុំទាំងឡាយ
គួរតែថ្វាយបង្គំបុគ្គលនោះផង គួរតែក្រោកទទួលបុគ្គលនោះផង គួរតែនិមន្ត

យ្យាមបំ អាសនេនបំ ឯមន្តេយ្យាម អកំឯមន្តេយ្យាម-
បំ ឯំ ឥវបិណ្ឌកាតសេនាសនគិលានប្បច្ចយភេសជ្ជ-
បរិក្ខារេហិ ឆម្ភិកំបិស្ស រក្ខាវរណគុត្តឹ សំវិនហេយ្យា-
មាតិ ។ តំ កឹ មញ្ញសិ មហារាជ យនិ ឃំ សន្តេ
ហោតិ វា សង្ឃដ្ឋកំ សាមញ្ញផលំ នោ វាតិ ។ អន្ធា
ខោ ភន្តេ ឃំ សន្តេ ហោតិ សង្ឃដ្ឋកំ សាមញ្ញផលន្តិ ។
ឥធ ខោ តេ មហារាជ មយា បឋមំ ឥន្ទ្រ វ ឆម្ភេ
សង្ឃដ្ឋកំ សាមញ្ញផលំ បញ្ញត្តន្តិ ។

(១០១) សក្កា បន ភន្តេ អញ្ញេបិ ឯវមេវ ឥន្ទ្រ វ
ឆម្ភេ សង្ឃដ្ឋកំ សាមញ្ញផលំ បញ្ញបេតុន្តិ ។ សក្កា
